## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រនៃ
# យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
# ២០១៤ - ២០១៨

## ៣. ទិសដៅជាយុទ្ធសាស្ត្រ ឆ្ពោះទៅឆ្នាំ ២០៣០



ខែ ធ្នូ ឆ្នាំ ២០១៧

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

# ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងជាយុទ្ធសាស្ត្រនៃ
# យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
# ២០១៤ - ២០១៨

## ៣. ទិសដៅជាយុទ្ធសាស្ត្រ ឆ្ពោះទៅឆ្នាំ ២០៣០



ខែ ធ្នូ  ឆ្នាំ ២០១៧

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

# មាតិកា

សេចក្តីថ្លែងអំណរគុណ ........ ១
អក្សរកាត់ និងពាក្យកាត់ ........ ៣
១. សេចក្តីផ្តើម ........ ៥
២. វឌ្ឍនភាពមកទល់បច្ចុប្បន្ន ........ ៧
៣. បញ្ហាដែលនៅសេសសល់ ........ ១០
៤. បញ្ហានានាដែលលេចឡើងថ្មី ........ ១៥
៥. យុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ... ១៧
៦. ការរៀបចំអភិបាលកិច្ចសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ........ ២៨
៧. អនុសាសន៍ និងសេចក្តីសន្និដ្ឋាន ........ ៣១
បញ្ជីឯកសារយោង ........ ៣៤

# សេចក្តីថ្លែងអំណរគុណ

ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) និងជាប្រធានក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានសេចក្តីសោមនស្សរីករាយសូមប្រកាសផ្សព្វផ្សាយលទ្ធផលរកឃើញនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ លើ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ២០១៤-២០១៨។ ឯកឧត្តមសូមថ្លែងអំណរគុណ ចំពោះការរួមចំណែកដ៏មានសារៈសំខាន់ និងការចូលរួមដ៏សកម្ម ពីមន្ត្រីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួងពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ តំណាងសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ស្តីពី ការវាយតម្លៃពាក់កណ្តាលអាណត្តិលើ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនេះ។ បន្ថែមលើសពីនេះ ឯកឧត្តម **យឹម ឆៃលី** សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ដែលបានជួយគ្រប់បែបយ៉ាងដល់ការវាយតម្លៃនេះ ដោយមានការចូលរួមពីសហភាពអឺរ៉ុប ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) ទីភ្នាក់ងារសហប្រជាជាតិនានា ដូចជា អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ (FAO) អង្គការស្បៀងអាហារពិភពលោក (WFP) និងមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) ព្រមទាំងសម្ព័ន្ធសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភ ដែលដឹកនាំដោយ អង្គការហេលិន ខេល័រ អន្តរជាតិ (Helen Keller International)។ ឯកឧត្តមក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះធនាគារពិភពលោក ដែលបានជួយធ្វើការពិនិត្យល្អិតល្អន់លើការងារនេះ។

ការងាររបស់គណៈកម្មាធិការផ្តល់ប្រឹក្សា ដែលត្រូវបានបង្កើតឡើងជាផ្លូវការ សម្រាប់ការវាយតម្លៃពាក់កណ្តាលអាណត្តិលើការអនុវត្តយុទ្ធសាស្ត្រនេះ ហើយដែលមានឯកឧត្តម **ឌី ច័ន្ទផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជាប្រធាន និងសមាជិកជាតំណាងមកពីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងការតម្រង់ទិសដល់ដំណើរការក៏ដូចជាការបញ្ជាក់ផ្ទៀងផ្ទាត់លទ្ធផលនៃការពិនិត្យឡើងវិញនេះផងដែរ។ ឯកឧត្តមសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះលោកស្រី **Claire Van der Vaeren** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងលោកស្រី **Veena Reddy** នាយកបេសកកម្មស្តីទីរបស់ USAID ដែលបានចូលរួមសហការប្រកបដោយការប្តេជ្ញាចិត្តខ្ពស់។ សមាជិកដែលមាននៅក្នុងក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានចូលរួមនៅក្នុងការវាយតម្លៃពាក់កណ្តាលអណត្តិនេះ ហើយឯកឧត្តមសូមធ្វើការវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងគាំទ្ររបស់ពួកគេក្នុងការជម្នះបញ្ហាប្រឈម ដែលកំពុងបន្តកើតមានឡើងក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។ វេទិកាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក៏ជាវេទិកាដ៏សំខាន់ សម្រាប់ធ្វើការផ្សព្វផ្សាយវឌ្ឍនភាព ដែលសម្រេចបានជាមួយនឹងការវាយតម្លៃនេះ ហើយក៏ជាវេទិកាសម្រាប់ការពិភាក្សាពីលទ្ធផលនានាផងដែរ។

បន្ទាប់ពីមានការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញយ៉ាងទូលំទូលាយរួចមក ឯកសារចុងក្រោយត្រូវបានប្រកាសផ្សព្វផ្សាយដោយឯកឧត្តម **យឹម ឆៃលី** ក្នុងនាមតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា លោកស្រី **Claire Van der Vaeren** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងលោក **David Kaatrud** ប្រធានការិយាល័យតំបន់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការស្បៀងអាហារពិភពលោក នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៨។ ឯកសារផ្សេងគ្នាចំនួនបីត្រូវបានរៀបចំឡើងសម្រាប់ការវាយតម្លៃពាក់កណ្តាលអណត្តិនេះ ដោយបានបញ្ចូលគំនិតយោបល់ជាធាតុចូលពីប្រភពផ្សេងៗ

ហើយពង្រាងឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយ និងដាក់ឱ្យពិភាក្សាយ៉ាងទូលំទូលាយ។ ឯកសារទាំងបីនេះត្រូវបានរៀបចំឡើង ផ្អែកទៅតាមឯកសារយោងជាច្រើន និងការវិភាគមួយចំនួនដែលកំពុងបន្តធ្វើ។ ឯកសារបីសំខាន់ៗនៃការវាយតម្លៃពាក់កណ្តាលអាណត្តិលើយុទ្ធសាស្ត្រនេះ រួមមាន៖

១. វឌ្ឍនភាពដែលសម្រេចបានត្រឹមឆ្នាំ ២០១៦

២. ស្ថានភាពបច្ចុប្បន្ន ឆ្នាំ ២០១៧

៣. ទិសដៅជាយុទ្ធសាស្ត្រ ឆ្ពោះទៅឆ្នាំ ២០៣០

ខណៈពេលដែលឯកសារទាំងនេះត្រូវបានផ្សព្វផ្សាយជាមួយគ្នា ឯកសារទាំងនេះជាឯកសារដោយឡែកៗពីគ្នា ដោយហេតុថា ឯកសារនីមួយៗ គឺជាការវិភាគដោយឡែកៗពីគ្នា។ ដូចដែលបង្ហាញនៅក្នុងឯកសារទាំងនេះ ការវាយតម្លៃពាក់កណ្តាលអាណត្តិលើយុទ្ធសាស្ត្រនេះ បានផ្តល់នូវរបកគំហើញសំខាន់ៗជាច្រើន ព្រមទាំងផ្តល់នូវការណែនាំអំពីជំហានបន្ទាប់ផងដែរ។ ការវាយតម្លៃនេះក៏ជាមូលដ្ឋានសម្រាប់រៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ ២០១៩-២០២៣ និងជាមូលដ្ឋានជួយជំរុញកិច្ចខិតខំប្រឹងប្រែងនៅថ្នាក់ជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាអាហារូបត្ថម្ភផងដែរ។

ដំណើរការពិគ្រោះយោបល់ និងការពិភាក្សានេះ ក៏ជាច្រកសំខាន់សម្រាប់ជួយឱ្យមានការរៀនសូត្រ និងការកសាងសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ។ គិតត្រឹមចុងឆ្នាំ២០១៦ មានការសម្រេចបាននូវវឌ្ឍនភាពជាច្រើនក្នុងការឈានទៅសម្រេចគោលបំណងជាយុទ្ធសាស្ត្រនានា។ ទិសដៅរបស់យើងក្នុងដំណើរផ្លូវឆ្ពោះទៅមុខ ត្រូវបានដាក់ចេញយ៉ាងជាក់ច្បាស់។ យុទ្ធសាស្ត្រនេះជួយតម្រង់ទិសសកម្មភាពដែលត្រូវអនុវត្តសម្រាប់រយៈពេលនៅសេសសល់ រហូតដល់ចុងឆ្នាំ ២០១៨។ គ្រប់គោលនយោបាយ និងកម្មវិធីតាមវិស័យទាំងអស់ គួរបញ្ចូលទិសដៅទាំងនេះ ហើយគោលនយោបាយ និងកម្មវិធីនីមួយៗសុទ្ធតែរួមចំណែកដល់ការសម្រេចទិសដៅទាំងនេះ ទៅតាមតួនាទី និងការទទួលខុសត្រូវរបស់វិស័យនីមួយៗ។ លើសពីនេះ ក៏ចាំបាច់ត្រូវមានការពង្រឹងយន្តការសម្របសម្រួលការងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិផងដែរ ជាពិសេស សំដៅធានាយ៉ាងណាឱ្យមានការកសាងសមត្ថភាព ពិនិត្យតាមដាន និងវាយតម្លៃវឌ្ឍនភាព នៅចុងរយៈពេលនៃយុទ្ធសាស្ត្រនេះ។ យើងត្រូវធានាយ៉ាងណាឱ្យគ្រប់ភាគីទាំងអស់ធ្វើការងាររួមគ្នា និងត្រូវបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចប់ភាពអត់ឃ្លាននៅកម្ពុជាឱ្យបានត្រឹមឆ្នាំ ២០៣០។ យើងទាំងអស់គ្នាអាចបង្ហាញពីគំរូភាពដល់ប្រទេសនានា នៅក្នុងសកលលោកទាំងមូល តាមរយៈការខិតខំធ្វើការងារឆ្ពោះទៅសម្រេចគោលដៅនេះ ពោលគឺការធ្វើការងាររួមគ្នាជាធ្លុងមួយ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងក្រោមតម្រាយផ្លូវនៃយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការដែលមានស្រាប់ដទៃទៀត។

# អក្សរកាត់ និងពាក្យកាត់

## ស្ថាប័នរដ្ឋាភិបាល

| | | |
|---|---|---|
| CARD | Council for Agricultural and Rural Development | ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| NMCHC | National Maternal and Child Health Center | មជ្ឈមណ្ឌល ជាតិគាំពារ មាតា និងទារក |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |

## អង្គការសហប្រជាជាតិ/អង្គការមិនមែនរដ្ឋាភិបាល/ស្ថាប័ននានា

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| CSA | Civil Society Alliance | សម្ព័ន្ធសង្គមស៊ីវិល |
| FAO | Food and Agriculture Organization of the United Nations | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ |
| HKI | Helen Keller International | ហេលិន ខេល័រ អន្តរជាតិ |
| HLPE | High-Level Panel of Experts | គណៈកម្មាធិការជំនាញកម្រិតខ្ពស់ |
| IFPRI | International Food Policy Research Institute | វិទ្យាស្ថានអន្តរជាតិស្រាវជ្រាវគោលនយោបាយស្បៀងអាហារ |
| SUN | Scaling Up Nutrition | ចលនាបង្កើនអាហារូបត្ថម្ភ |
| SUN-CSN | SUN Civil Society Network | បណ្ដាញសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភ |
| UN | United Nations | អង្គការសហប្រជាជាតិ |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNFPA | United Nations Population Fund | មូលនិធិសហប្រជាជាតិដើម្បីប្រជាជន |

| | | |
|---|---|---|
| UNICEF | United Nations Children's Fund | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| USAID | United States Agency for International Development | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| WFP | World Food Programme | កម្មវិធីស្បៀងអាហារពិភពលោក |
| WHO | World Health Organization | អង្គការសុខភាពពិភពលោក |

## ពាក្យកាត់ផ្សេងៗ

| | | |
|---|---|---|
| HDI | Human Development Index | សន្ទស្សន៍នៃការអភិវឌ្ឍន៍មនុស្ស |
| HEF | Health Equity Fund | មូលនិធិសមធម៌សុខភាព |
| MTSR | Mid-Term and Strategic Review | ការត្រួតពិនិត្យពាក់កណ្ដាលអាណត្តិលើយុទ្ធសាស្ត្រ |
| NCDs | Non-Communicable Diseases | ជំងឺមិនឆ្លង |
| NSSF | National Social Security Fund | បេឡាជាតិរបបសន្តិសុខសង្គម |
| NSFSN | National Strategy for Food Security and Nutrition | យុទ្ធសាស្ត្រជាតិ ស្ដីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ |
| NSPPF | National Social Protection Policy Framework | ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម |
| SDG | Sustainable Development Goal | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| WASH | Water, Sanitation and Hygiene | ទឹកស្អាត និងអនាម័យ |
| WRA | Women of Reproductive Age | ស្ត្រីវ័យបន្តពូជ |

# ១. សេចក្តីផ្តើម

សិទ្ធិទទួលបានស្បៀង គឺជាសិទ្ធិមនុស្សជាមូលដ្ឋានដែលមានការទទួលស្គាល់ដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័ននៅឆ្នាំ១៩៩២ និងបានគាំទ្រពី កិច្ចប្រជុំកំពូលអង្គការសហប្រជាជាតិ និងគំនិតផ្តួចផ្តើមនានារួមមាន៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០ ជាពិសេសគោលដៅទី២ ដែលមានគោលដៅឆ្ពោះទៅកាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យ។ សិទ្ធិទទួលបានស្បៀង ទទួលស្គាល់ថាការបញ្ចប់ភាពអត់ឃ្លាន គឺមានន័យថាធានានូវការទទួលបានអាហារដែលសម្បូរជីវជាតិសម្រាប់ក្រុមដែលងាយរងគ្រោះបំផុត ការបង្កើនផលិតកម្មកសិកម្ម តាមរយៈប្រព័ន្ធស្បៀង ដែលមានភាពធន់ និងមាននិរន្តរភាព ព្រមទាំងដោះស្រាយមូលហេតុជាច្រើន នៃបញ្ហាអាហារូបត្ថម្ភ ដែលរួមទាំងសុខភាព និងអនាម័យផងដែរ។

2 ZERO HUNGER

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភប្រសើរជាងមុន និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព**

២.១ ត្រឹមឆ្នាំ ២០៣០ បញ្ចប់ភាពអត់ឃ្លាននិងធានាថាប្រជាពលរដ្ឋទាំងអស់ ជាពិសេសជនក្រីក្រ និងប្រជាពលរដ្ឋដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ រួមទាំង កុមារទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ នៅគ្រប់រដូវ"

២.២ ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃបញ្ហាអាហារូបត្ថម្ភរួមទាំងការសម្រេចបាននៅឆ្នាំ២០២៥នូវ ចំណុចដៅដែលបានឯកភាពក្នុងកម្រិតអន្តរជាតិស្តីពីភាពក្រិសក្រិន និងភាពស្គមស្គាំងរបស់កុមារក្រោមអាយុ៥ឆ្នាំ និងដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន និងចាស់ជរា។

២.៣ ត្រឹមឆ្នាំ ២០៣០ ទទួលបានកំណើនទ្វេដងនៃផលិតផលកសិកម្ម និងចំណូលរបស់ផលិតករធុនតូច ជាពិសេសស្ត្រី ជនជាតិដើមភាគតិចគ្រួសារកសិករអ្នកចិញ្ចឹមសត្វនិងអ្នកនេសាទ រួមទាំងតាមរយៈការធានា និងការទទួលបាននូវសមភាពដីធ្លី ធនធាន និងធាតុចូលសម្រាប់ ផលិតកម្មដទៃទៀត ចំណេះដឹង សេវាហិរញ្ញវត្ថុទីផ្សារ និងកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម និងការងារក្នុងផ្នែកមិនមែនកសិកម្ម។

ក្នុងនាមជាសមាជិករបស់អាស៊ាន កម្ពុជាមានការប្តេជ្ញាចិត្តក្នុងការលុបបំបាត់អសន្តិសុខស្បៀងនិងភាពអត់ឃ្លាន។ ប្រទេសកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ក្នុងការកែលម្អស្ថានភាពសន្តិសុខស្បៀងនៅទូទាំងប្រទេស ដោយប្រកាន់យកអភិក្រមពហុវិស័យ ដើម្បីដោះស្រាយបញ្ហាអាហារូបត្ថម្ភនិងភាពក្រីក្រ ការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រនានា ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងការខិតខំប្រឹងប្រែងដើម្បីបញ្ជ្រាបវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងរបៀបវារៈដទៃទៀត។

ការលើកកម្ពស់សន្តិសុខស្បៀង គឺជាអាទិភាពអភិវឌ្ឍន៍ដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា (២០១៤-២០១៨) (RGC, 2013) ដែលពង្រឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលនៅក្នុងវិស័យសមភាពយេនឌ័រ អាហារូបត្ថម្ភ និងកិច្ចគាំពារសង្គម និងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) (RGC, 2014b) ដែលបានរៀបចំឡើង សម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ និងផ្សារភ្ជាប់យុទ្ធសាស្ត្រនេះ ទៅនឹងគ្រប់គោលនយោបាយជាតិតាមវិស័យនានា។ ដើម្បីធានាឱ្យមានយន្តការមួយសមស្រប សម្រាប់សម្របសម្រួលសកម្មភាពរួមគ្នានៅកម្រិតអន្តរវិស័យ ក្នុងទិសដៅលើកកម្ពស់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ រាជរដ្ឋាភិបាលកម្ពុជា បានប្រគល់ភារកិច្ចឱ្យក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ នូវអាណត្តិរៀបចំ និងអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

នៅឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ២០១៤-២០១៨(RGC,2014a) ជាមួយគោលដៅដែលចែងថា“**ត្រឹមឆ្នាំ២០១៨ ប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងអសន្តិសុខស្បៀង មានលទ្ធភាពផ្នែករូបវ័ន្ត សង្គម និងសេដ្ឋកិច្ច ប្រសើរជាងមុនគួរឱ្យកត់សំគាល់ ក្នុងការទទួលបាន ស្បៀងអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្របនឹងតម្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំង ប្រើប្រាស់ស្បៀងអាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេ មានសុខភាពល្អនិងមានផលិតភាពខ្ពស់។**”យុទ្ធសាស្ត្រនេះគាំទ្រដោយផែនទីបង្ហាញផ្លូវដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភ នៅកម្ពុជា២០១៤-២០២០ (MoH, 2014) និងការប្តេជ្ញាចំពោះគោលដៅទី២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៅក្នុងផែនការសកម្មភាពជាតិស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា(២០១៦-២០២៥)(RGC,2016)។ វឌ្ឍនភាពនេះកំពុងស្ថិតក្រោមការពិនិត្យមើលតាមរយៈការពិនិត្យឡើងវិញនូវសូចនាករក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ សូចនាករតាមដានរួមគ្នា និងការធ្វើមូលដ្ឋានីយកម្មសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ ២០១៧។

(បន្តមកពីទំព័រទី៥)

២.៤ ត្រឹមឆ្នាំ២០៣០ ធានានូវប្រព័ន្ធផលិតកម្មស្បៀងដែលមានចីរភាពអនុវត្តកសិកម្មដែលធន់ទ្រាំនឹងបម្រែបម្រួលអាសធាតុដែលអាចបង្កើនផលិតភាព និងផលិតកម្ម ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ីនិងពង្រឹងសមត្ថភាពបន្សាំនឹងបម្រែបម្រួលអាកាសធាតុធ្ងន់ធ្ងរ គ្រោះរាំងស្ងួត ទឹកជំនន់ និងគ្រោះមហន្តរាយដទៃទៀត និងធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវគុណភាពដី។

២.៥ ត្រឹមឆ្នាំ២០២០ រក្សាការធ្វើពិពិធកម្មហ្សែន នៃគ្រាប់ពូជដំណាំដាំដុះ ការផ្សាំពូជសត្វ និងប្រភេទសត្វព្រៃដែលពាក់ព័ន្ធដូចជាតាមរយៈការគ្រប់គ្រងសមស្របលើការបង្កើតធនាគារគ្រាប់ពូជ និងការធ្វើពិពិធកម្ម នៅកម្រិតជាតិ តំបន់ និងអន្តរជាតិ និងលើកកម្ពស់ការទទួលបានចំណែកប្រកបដោយយុត្តិធម៌ និងសមធម៌នៃផល ប្រយោជន៍ពីការប្រើប្រាស់ធនធានហ្សែន និងចំណេះដឹងប្រពៃណីដែលពាក់ព័ន្ធ ដូចការឯកភាពជាអន្តរជាតិ។*

ប្រភព៖ (UN, n.d.)

* គោលដៅទី ២.៥ ពុំមាននៅក្នុងការពិនិត្យពាក់កណ្តាលអាណត្តិ និងជាលក្ខណៈយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នេះទេ។

ជាមួយយុទ្ធសាស្ត្រគន្លឹះមួយចំនួន ដែលទាក់ទងនឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ដែលត្រូវការឱ្យមានការពិនិត្យឡើងវិញនិងរៀបចំជាថ្មី។ ការពិនិត្យនៅពាក់កណ្តាលអាណត្តិលើការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភឆ្នាំ២០១៤-២០១៨ ត្រូវបានចាប់ផ្តើមធ្វើឡើងនៅខែមេសា ឆ្នាំ២០១៧ ដើម្បីពិនិត្យមើលសមិទ្ធផលដែលសម្រេចបានកន្លងមក វិភាគលើបរិបទបច្ចុប្បន្ននៃវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា និងដើម្បីត្រៀមរៀបចំយុទ្ធសាស្ត្រថ្មីនាពេលអនាគត។ ដំណើរការពិនិត្យនៅពាក់កណ្តាលអាណត្តិរួមមាន ការប្រមូលព័ត៌មាន តាមរយៈការអង្កេតអំពីសមិទ្ធផលកន្លងមក ការពិនិត្យឯកសារនានាដែលមានស្រាប់ ការសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗ និងការពិគ្រោះយោបល់ផ្លូវការជាបន្តបន្ទាប់(CARD, 2017b, 2017c) នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមានគោលបំណងដូចតទៅ៖

១ ពិនិត្យសមិទ្ធផលនានាដែលសម្រេចបាននាពេលកន្លងមក របស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ គិតត្រឹមឆ្នាំ ២០១៦

២ ពិនិត្យការប្រឈម និងឧបសគ្គនានាដែលរារាំងដល់ការអនុវត្តយុទ្ធសាស្ត្រនេះ និងរកមធ្យោបាយដើម្បីដោះស្រាយបញ្ហា

៣ ពិចារណាសកម្មភាពដែលនៅពុំទាន់បានអនុវត្តនៅក្រោមយុទ្ធសាស្ត្រនេះ មកទល់ចុងឆ្នាំ ២០១៦ និងធ្វើបច្ចុប្បន្នភាពផែនការនានា ដើម្បីអនុវត្តបញ្ចប់នៅត្រឹមឆ្នាំ ២០១៨

៤ ធ្វើការវិភាគខ្ទីជាក់លាក់មួយអំពីស្ថានភាពបច្ចុប្បន្នសម្រាប់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈការវិភាគដ៏ទូលំទូលាយ និងដោយផ្តោតលើទស្សនវិស័យរបស់អ្នកពាក់ព័ន្ធនានា

៥ រៀបចំផែនទីបង្ហាញផ្លូវមួយឆ្ពោះទៅឆ្នាំ២០៣០ និងផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ថ្មីសម្រាប់ ឆ្នាំ២០១៩-២០២៣

៦ ផ្សព្វផ្សាយលទ្ធផលនានាដែលបានមកពីដំណើរការការពិនិត្យនៅពាក់កណ្តាលអាណត្តិឱ្យបានទូលំទូលាយ

៧ ធានាថា គ្រប់ទិន្នន័យ ឧបករណ៍ ដែលបានប្រើប្រាស់ និងសម្ភារៈនានាដែលបានចងក្រងសម្រាប់ដំណើរការការពិនិត្យនៅពាក់កណ្តាលអាណត្តិត្រូវបានរក្សាទុកឱ្យមានសុវត្ថិភាព និងអាចប្រើប្រាស់បន្តទៀតបាន តាមរយៈយន្តការផ្តល់ព័ត៌មានរួមមួយ។

សេចក្តីសង្ខេបនេះ មានគោលដៅផ្តល់ការវិភាគរួមមួយសម្រាប់ការបន្សុីយុទ្ធសាស្ត្រជាតិ និងយុទ្ធសាស្ត្រនានារបស់ដៃគូ។

## ២. វឌ្ឍនភាពមកទល់បច្ចុប្បន្ន

វឌ្ឍនភាពបានកើតឡើងលើគ្រប់វិស័យនៃការអនុវត្តសកម្មភាពអាទិភាព ក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (២០១៤-២០១៨)។ ជាការពិត គ្រប់សកម្មភាពអាទិភាពទាំងអស់កំពុងស្ថិតក្នុងការអនុវត្ត ទោះបីវិសាលភាពគ្របដណ្តប់នៅទូទាំងប្រទេស ពុំដូចគ្នាក៏ដោយ។ អភិក្រមពេញលេញក្នុងការប្រយុទ្ធប្រឆាំងបញ្ហាអាហារូបត្ថម្ភ បានទទួលការគាំទ្រយ៉ាងពេញទំហឹង។ ការគាំទ្រនេះមានរាប់ចាប់ពីថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៅកម្ពុជា និងមានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីថ្លែងការណ៍គោលនយោបាយ និងការណែនាំនៅកម្រិតថ្នាក់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នានា ព្រមទាំងកិច្ចប្រឹងប្រែងរួមគ្នានៅទូទាំងប្រទេសផងដែរ។ ការគាំទ្រនេះ បានផ្តោតលើការយល់ដឹងថាមូលហេតុចំបងនៃបញ្ហាអាហារូបត្ថម្ភ គឺជាប្រធានបទដែលមានការពាក់ព័ន្ធអន្តរវិស័យ ហើយបញ្ហាខ្វះ ទាមទារឱ្យមានអភិក្រមចម្រុះ (ដែលរួមបញ្ចូលវិស័យកសិកម្ម សុខាភិបាល អភិវឌ្ឍន៍ជនបទ និងអប់រំ។ល។)

> "កម្ពុជាត្រូវបានគេពិនិត្យឃើញថាមាន កំណើនសេដ្ឋកិច្ចដ៏រឹងមាំដែលធ្វើឲ្យមានការកែលម្អវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ..."

កម្ពុជាត្រូវបានគេពិនិត្យឃើញថាមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ដែលមានតួលេខមធ្យម ៧,៧%ក្នុងមួយឆ្នាំ។ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងទៅនេះ ហើយប្រទេសនេះត្រូវគេរំពឹងថានឹងបន្តរក្សាអត្រាកំណើនជាមធ្យមក្នុងកម្រិត ៧% ក្នុងរយៈពេលមធ្យម។ កំណើនសេដ្ឋកិច្ចពិពិធកម្មនិងការលើកកម្ពស់ជីវភាពរស់នៅអាចនាំឱ្យមានការធ្វើឱ្យប្រសើរឡើងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដូចមានលើកឡើងនៅក្នុងពិន្ទុសម្រាប់ សន្ទស្សន៍ភាពអត់ឃ្លានពិភពលោក ឆ្នាំ២០១៧ (von Grebmer, et al., 2017)។ ទោះបីជាភាពអត់ឃ្លាននៅតែជាបញ្ហាធ្ងន់ធ្ងរនៅឡើយ ក៏ប្រទេសកម្ពុជាត្រូវបានគេមើលឃើញថា ការកែលម្អភាពអត់ឃ្លានមានកំណើនយ៉ាងឆាប់រហ័ស ហើយបច្ចុប្បន្នកំពុងឈានទៅជាប្រទេស ដែលមានចំណាត់ថ្នាក់មធ្យមក្នុងការកាត់បន្ថយភាពអត់ឃ្លាន។ នៅក្នុងចំណាត់ថ្នាក់ជាសកល កម្ពុជាសម្រេចបានអត្រាខ្ពស់បំផុតនៃការកាត់បន្ថយភាពអត់ឃ្លាន ក្នុងចំណោមប្រទេសដែលមានភាពអត់ឃ្លានធ្ងន់ធ្ងរ ឬខ្ពស់ជាងនេះ នៅក្នុងការដាក់ពិន្ទុសន្ទស្សន៍ភាពអត់ឃ្លានពិភពលោក សម្រាប់អំឡុងឆ្នាំ ២០០០-២០១៧។

ក្របខ័ណ្ឌផែនការដ៏រឹងមាំ និងយន្តការសម្រាប់សម្របសម្រួលកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ដែលមានស្រាប់ត្រូវបានដាក់ចេញឱ្យអនុវត្ត ហើយរាជរដ្ឋាភិបាលកម្ពុជា អំពាវនាវដល់ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ឱ្យបន្តកិច្ចសហប្រតិបត្តិការរបស់ខ្លួន ក្នុងការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពី

សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (២០១៤-២០១៨) ផែនការសកម្មភាពជាតិស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា (២០១៦-២០២៥) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម (២០១៤-២០១៨) (MAFF, 2014) ផែនទីបង្ហាញផ្លូវដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភនៅកម្ពុជា (២០១៤-២០២០) និងផែនការយុទ្ធសាស្ត្រតាមវិស័យដទៃទៀតដែលទាក់ទង នឹងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីធានាថាប្រជាពលរដ្ឋកម្ពុជាមានលទ្ធភាពផ្នែករូបវ័ន្ត សង្គម និងសេដ្ឋកិច្ចប្រសើរជាងមុនគួរឱ្យកត់សំគាល់ ក្នុងការទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ ដើម្បីឱ្យស្របនឹងតម្រូវការផ្នែកចំណីអាហារ និងចំណង់ចំណូលចិត្តក្នុងការទទួលទានអាហាររបស់ពួកគេ ព្រមទាំងប្រើប្រាស់ស្បៀងអាហារឱ្យបានប្រសើរបំផុត ដើម្បីធ្វើឱ្យជីវិតរស់នៅរបស់ពួកគេមានសុខភាពល្អ និងមានផលិតភាពខ្ពស់។

## ២.១ ភាពមានស្បៀង

ផលិតកម្មកសិកម្ម ដែលផ្តោតលើដំណាំស្រូវ និងលើដំណាំរួមផ្សំដទៃទៀត បានកើនឡើងលឿនជាងកំណើនប្រជាជន និងតម្រូវការដែលបានធ្វើឱ្យប្រសើរឡើងភាពមានស្បៀង។ តាំងពីឆ្នាំ១៩៩៦មកកម្ពុជាផលិតស្រូវបានគ្រប់គ្រាន់ ដែលសម្រួលឱ្យមានកំណើនការនាំចេញអង្ករ ដោយមានផលិតផលកើនឡើងពីប្រមាណ ៤.000.000តោន ដល់ជិត ១0.000.000តោន នៅចន្លោះឆ្នាំ២000 និង ២០១៦ (World Bank, 2017; MAFF, 2017)។ វត្តមានច្រើនលើសលុបនៃបរិមាណស្រូវនៅក្នុងផលិតកម្មកសិកម្មមានន័យថា បច្ចុប្បន្នផលិតកម្មស្រូវគ្របដណ្តប់ប្រមាណ ៧២ភាគរយនៃផ្ទៃដីដាំដុះ។ ការបរិភោគអាហារមិនគ្រប់គ្រាន់បានធ្លាក់ចុះជាខ្លាំងពីកម្រិតខ្ពស់៣៦,៧%នៅឆ្នាំ១៩៩៨មកត្រឹមប្រមាណ ១៤% នៅឆ្នាំ២០១៥ នៃចំនួនប្រជាជន (FAO, 2017a) ដោយផ្អែកលើតារាងតុល្យភាពស្បៀងថ្នាក់ជាតិ និងដែលជាការគូសបញ្ជាក់អំពីការរួមផ្សំរវាងការកែលម្អផលិតកម្មស្បៀងនិងការសម្រួលដល់ការនាំចេញ និងការនាំចូល បានធ្វើឱ្យមានការប្រែប្រួលតម្រូវការអាហារថាមពលរបស់ប្រជាពលរដ្ឋកាន់តែល្អប្រសើរ។

## ២.២ ភាពទទួលបានស្បៀង

ទន្ទឹមនឹងការកែលម្អភាពមានស្បៀង ក៏មានការកែលម្អទៅលើភាពទទួលបានស្បៀងផងដែរ ដែលមានភស្តុតាងបង្ហាញតាមរយៈការថយចុះនៃអត្រាភាពក្រីក្រ និងការកែលម្អនៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា (HDI)។ ចាប់ពីឆ្នាំ ១៩៩០ ដល់ ២០១៥ អត្រាកំណើននៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្សប្រចាំឆ្នាំរបស់ប្រទេសកម្ពុជា ដែលមាន១,៨៤% មានកម្រិតខ្ពស់ជាងតួលេខមធ្យមនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលបច្ចុប្បន្នស្ថិតនៅត្រឹម ១,៣៥% ដូច្នេះធ្វើឱ្យកម្ពុជាស្ថិតក្នុងចំណោមប្រទេសចំនួនប្រាំពីរលើពិភពលោកដែលមានអត្រាកំណើននៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្សឆាប់រហ័សជាងគេ និងស្ថិតក្នុងលំដាប់ទី១៤៣ ក្នុងចំណោមប្រទេសចំនួន១៨៨។ ភាគរយនៃចំនួនប្រជាជនកម្ពុជា ដែលរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រនៅថ្នាក់ជាតិបានធ្លាក់ចុះពី ៥៣,២% នៅឆ្នាំ២00៤ មកត្រឹម ១៣,៥% នៅឆ្នាំ២០១៤ (MEF, 2016) ដោយផ្អែកលើចំនួនប្រជាជនដែលស្ថិតក្នុងភាពក្រីក្រខាងប្រាក់ចំណូល។ ចំនួនប្រជាជនដែលរស់នៅក្នុងភាពក្រីក្រផ្អែកលើកត្តាចម្រុះច្រើនយ៉ាង មានអត្រាខ្ពស់ជាង ពោលគឺស្ថិតនៅលំដាប់៣១,៦%នៃចំនួនប្រជាជនសរុប (UNDP, 2016)។ កំណើនសេដ្ឋកិច្ចកម្ពុជា បានធ្វើឱ្យផលិតផលក្នុងស្រុកសរុបក្នុងម្នាក់ៗកើនពី ១.២១៥ដុល្លាអាមេរិកនៅឆ្នាំ២០១៥ ដល់ ១.៤៣៥ ដុល្លារ ក្នុងឆ្នាំ ២០១៧ (Cabinet of the Prime Minister, 2018) ក្នុងខណៈពេលដែលការចំណាយរបស់មនុស្សម្នាក់ៗមានការកើនឡើងផងដែរ។ ការចំណាយលើស្បៀងអាហារ បានកើនឡើង ៥,៥% ចន្លោះឆ្នាំ២00៩ និង ២០១៥ ហើយក្នុងអំឡុងពេលដូចគ្នានេះដែរ ការចំណាយលើសម្ភារៈក្រៅពីស្បៀងអាហារបានកើនឡើង១១%។ កត្តានេះ

បានបង្ហាញពីការកើនឡើងនៃអំណាចទិញដែលរួមទាំងក្នុងចំណោមក្រុមជនក្រីក្របំផុតក្នុងសង្គម។កំណើននៃការចំណាយជាវិជ្ជមានបែបនេះ មានន័យថា បច្ចុប្បន្ននេះការចំណាយលើស្បៀងអាហារមានសមាមាត្រទាបជាង នៅក្នុងការចំណាយសរុប (NIS, 2009)។

## ២.៣ ការបឺតស្រូបស្បៀង

ភាគរយនៃចំនួនគ្រួសារដែលមានរបបអាហារមិនសម្បូរបែបគ្រប់គ្រាន់ បានថយចុះជាខ្លាំងពី ៤៦% នៅឆ្នាំ ២០០៨ មកត្រឹម ១២% នៅឆ្នាំ ២០១៤ (NIS, 2014)។ ភាពប្រសើរឡើងខាងប្រាក់ចំណូល និងទ្រព្យសម្បត្តិ កំណើនភាពចម្រុះនៃរបបអាហារ ការអប់រំ (ជាពិសេសការអប់រំមាតា) ការពង្រីកវិសាលភាពគ្របដណ្តប់ខាងសេវាថែទាំសុខភាព ការកែលម្អលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យ និងការលើកកម្ពស់អាកប្បកិរិយាទាក់ទងសុខភាព និងអាហារូបត្ថម្ភដូចជាការបំបៅដោះកូនតែមួយមុខជាពិសេសនៅតំបន់ជនបទ គឺជាកត្តាដែលធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ (NMCHC, 2016; UNICEF, 2016)។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះបរិយាកាសគោលនយោបាយកាន់តែអំណោយផល ក៏បានបង្កើនការយកចិត្តទុកដាក់ក្នុងការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភផងដែរ ជាមួយនឹងការគាំទ្រយ៉ាងម៉ឺងម៉ាត់ចំពោះវិធានចម្រុះលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ (RGC, 2014a; MoH, 2014)។

ការបឺតស្រូបស្បៀងមានទំនាក់ទំនងជិតស្និទ្ធ ទៅនឹងលទ្ធផលខាងអាហារូបត្ថម្ភ មានវឌ្ឍនភាពគួរឱ្យកត់សំគាល់។ អត្រាកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ (ក្រិសក្រិន) បានថយចុះពី ៥០% នៅឆ្នាំ ២០០០ មកត្រឹម ៣២% នៅឆ្នាំ ២០១៤ ដែលស្ថិតក្នុងរបត់សមស្របមួយ ឆៀបនឹងគោលបំណងដែលមានចែងនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។ នៅក្នុងអំឡុងពេលដូចគ្នានេះ អត្រាស្គមស្គាំងបានថយចុះពី ១៧% មកត្រឹម ៩,៦% ទន្ទឹមនឹងនេះ ស្ថានភាពស្លេកស្លាំងក្នុងចំណោមកុមារក្រោមអាយុ៥ឆ្នាំបានធ្លាក់ចុះពី ៦២% មកត្រឹម ៥៦% និងក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ (អាយុ១៥-៤៩ឆ្នាំ)បានធ្លាក់ចុះពី ៤៧% មក ៤៥%។ ស្របគ្នាជាមួយនិន្នាការនេះដែរ ចាប់ពីឆ្នាំ ១៩៩០មក ប្រទេសកម្ពុជាកាត់បន្ថយអត្រាមរណភាពមាតាបានច្រើនជាងពាក់កណ្តាល និងការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សាសម្រេចបានជិតដល់កម្រិតសកល (NIS et al., 2015; FAO, 2017a)។

## ២.៤ ស្ថិរភាពស្បៀង

ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានអនុម័តនៅឆ្នាំ២០១៥ ដាក់ចេញនូវនៅក្នុងក្របខ័ណ្ឌសម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយការត្រៀមបង្ការនិងការឆ្លើយតបដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដោះស្រាយវិបត្តិនានាដែលបណ្តាលពីគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ ដូចជា៖ ទឹកជំនន់ និងខ្យល់ព្យុះ។ លើសពីនេះ រាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខាលើក្របខ័ណ្ឌសេនដាយ (Sendai Framework) ស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ជាមួយនឹងការប្តេជ្ញា ដើម្បីដោះស្រាយភាពងាយរងគ្រោះដែលទាក់ទងនឹងអាកាសធាតុ។

ក្នុងករណីមានវិបត្តិ ឬគ្រោះមហន្តរាយ ការខ្ចីបុល(បន្ថែម) ដែលជាញឹកញាប់ក្នុងអត្រាការប្រាក់ខ្ពស់ហួសហេតុ គឺជាយុទ្ធសាស្ត្រទប់ទល់ដែលផ្តល់ផលអវិជ្ជមានទៅដល់គ្រួសារងាយរងគ្រោះ។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់អត្រាការប្រាក់ខ្ពស់បំផុតត្រឹម ១៨% សម្រាប់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលកាលពីមុនអត្រាការប្រាក់អាចមានកម្រិតខ្ពស់ចន្លោះពី ២០-៣០ ភាគរយ (Leng/NBC, 2016)។

# ៣. បញ្ហាដែលនៅសេសសល់

ទោះបីមានវឌ្ឍនភាពជាច្រើនឆ្ពោះទៅរកកំណើនប្រសើរជាងមុននៅថ្នាក់ជាតិ និងវឌ្ឍនភាពលើផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភក៏ដោយ ក៏បញ្ហាមួយចំនួននៅតែមាននៅឡើយ។ បញ្ហាទាំងនេះមានជាអាទិ៍ ភាពមិនស្មើគ្នានៃវឌ្ឍនភាពនៅទូទាំងប្រទេសក្នុងចំណោមក្រុមប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ស្របពេលដែលប្រទេសកម្ពុជានៅតែមានការយឺតយ៉ាវមួយចំនួននៃសូចនាករអភិវឌ្ឍមនុស្ស។ លើសពីនេះ និរន្តរភាពនៃវឌ្ឍនភាព អាចនឹងជួបបញ្ហាប្រឈមដោយសារតែវិបត្តិសេដ្ឋកិច្ច និងហានិភ័យនៃគ្រោះមហន្តរាយ ដូច្នេះត្រូវបង្កើនការយកចិត្តទុកដាក់លើការកាត់បន្ថយហានិភ័យ និងកសាងភាពធន់ (CARD, 2017a; RGC, 2017)។ បញ្ហាទាំងនេះ ត្រូវតែបានដោះស្រាយនៅក្នុងបរិបទនៃរបៀបវារៈឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ទន្ទឹមនឹងការផ្តោតលើគោលដៅទី២នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG2) ភាពអត់ឃ្លាននៅកម្រិតសូន្យ ដែលចាំបាច់ត្រូវបង្កើតឱ្យមានចំណងទាក់ទងច្បាស់លាស់ជាមួយគោលដៅសំខាន់ៗផ្សេងទៀតនៃការអភិវឌ្ឍប្រកបដោយចីរភាព និងជាពិសេសគោលដៅទី១- គ្មានភាពក្រីក្រ ទី៣- មានសុខភាព និងសុខុមាលភាពល្អ ទី៤- គុណភាពនៃការអប់រំ ទី៥- សមភាពយេនឌ័រ ទី៦- ទឹកស្អាត និងអនាម័យ ទី៨- ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច ទី១០- កាត់បន្ថយវិសមភាព ទី១៣- ចាត់វិធានការដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និង ទី១៧- ភាពជាដៃគូ។

## ៣.១ ភាពមានស្បៀង

តាមទស្សនវិស័យស្តីពីភាពមានស្បៀង ក្នុងពេលដែលផលិតកម្មស្រូវបានកើនឡើងយ៉ាងឆាប់រហ័ស ការផ្តោតទៅលើផលិតកម្មស្រូវតែមួយមុខបែបនេះ មានន័យថាពិពិធកម្មដំណាំនៅក្នុងប្រទេសនៅមានកម្រិត។ ពិពិធកម្មដំណាំនៅមានកម្រិតបាន ឆ្លុះបញ្ចាំងពីរបៀបនៃការបរិភោគអាហារក្នុងគ្រួសារ ដែលទោះបីភាពមានស្បៀងបានកើនឡើងក្នុងទីផ្សារក៏ដោយក៏បាយនៅតែជាផ្នែកសំខាន់ក្នុងរបបអាហារប្រចាំថ្ងៃ។

"ក្នុងពេលដែលផលិតកម្មស្រូវបានកើនឡើងយ៉ាងឆាប់រហ័ស ការផ្តោតទៅលើផលិតកម្មស្រូវតែមួយមុខបែបនេះ មានន័យថាពិពិធកម្មដំណាំនៅក្នុងប្រទេសនៅមានកម្រិត"

## ៣.២ ភាពទទួលបានស្បៀង

របាយប្រាក់ចំណូល និងការទទួលបានស្បៀង នៅតែជាបញ្ហាប្រឈម នៅពេលដែលអត្ថប្រយោជន៍នានានៃវឌ្ឍនភាពនៅពុំទាន់បានបែងចែកប្រកបដោយសមធម៌នៅឡើយ។ គ្រួសារនៅតាមជនបទប្រមាណ៨០% បានទទួលប្រាក់ចំណូលត្រឹម ៤០% នៃប្រាក់ចំណូលសរុប ចំណែក២០% ផ្សេងទៀត បានទទួល៦០% នៃប្រាក់ចំណូលសរុប (FAO et al., 2016)។ ក្រុមជនក្រីក្រទទួលបានកំណើនយឺតយ៉ាវជាងក្រុមអ្នកមាន ដោយ៥០%នៃប្រជាជនក្នុងចំណោមអ្នកក្រីក្រជាងគេ គឺពឹងផ្អែកលើប្រាក់ចំណូលតិចជាង ២,៥០ដុល្លាក្នុងមួយថ្ងៃ។

"គ្រួសារនៅជនបទប្រមាណ៨០% បានទទួលប្រាក់ចំណូលត្រឹម ៤០% នៃប្រាក់ចំណូលសរុប ចំណែក ២០% ទទួលបាន៦០% នៃប្រាក់ចំណូល..."

ផលប្រយោជន៍ខាងសេដ្ឋកិច្ច បានកើតឡើងនៅភ្នំពេញ ច្រើនជាងនៅក្នុងតំបន់ទំនាបឬតំបន់ទន្លេសាប ហើយគម្លាតខាងប្រាក់ចំណូល មានខ្ពស់បំផុតនៅភាគឦសាននៃផ្ទៃប្រទេស ដែលជាកន្លែងរស់នៅរបស់គ្រួសារដែលមានប្រាក់ចំណូលទាបជាងគេ (UNDP, 2017; WFP, 2017b)។ វិសមភាពនៃការទទួលបានស្បៀង មានន័យថា ក្នុងពេលដែលមានស្បៀងជាទូទៅ ភាពមិនអាចទិញបាននាំមកនូវរបបអាហារ

ដែលគ្មានភាពចម្រុះគ្រប់គ្រាន់ ដែលមានអត្រាខ្ពស់បំផុតក្នុងចំណោមគ្រួសារក្រីក្រជាងគេ ក្នុងនោះ ២២% នៃប្រជាពលរដ្ឋនៅក្នុងក្រុមដែលមានចំណូលតិចជាងគេត្រូវបានរកឃើញថា នៅក្នុងរបបអាហារមានភាពចម្រុះមិនគ្រប់គ្រាន់។ នៅភាគឦសាន គ្រួសាររហូតដល់ ៦៦% អាចពុំទទួលបានអាហារដែលមានជីវជាតិគ្រប់គ្រាន់ ដែលតាមធម្មតាងាយរកបានបំផុត (NIS, 2009, 2014; von Grebmer et al., 2014, 2017)។ ដូចគ្នានេះដែរ ស្ត្រីបន្តប្រឈមនឹងវិសមភាពនៃការទទួលបានស្បៀង ដែលធ្វើឱ្យមានផលប៉ះពាល់ដល់អាហារូបត្ថម្ភ (FAO, 2017b)។ ការប្រឈមដែលនៅតែបន្តមាន ទាក់ទងនឹងភាពក្រីក្រផ្នែកស្បៀង និងអាហារូបត្ថម្ភមានលក្ខណៈកាន់តែស្មុគស្មាញ ដោយសារតែបញ្ហាពាក់ព័ន្ធនឹងការទទួលបានកាលានុវត្តិភាពរបរចិញ្ចឹមជីវិត និងសេវាសង្គម។ ដើម្បីធានាការអភិវឌ្ឍដោយចីរភាពសម្រាប់ប្រជាពលរដ្ឋទាំងអស់ វិសាលភាពនៃវិសមភាពនេះ ទាមទារឱ្យមានការដោះស្រាយដែលជាផ្នែកមួយនៃរបៀបវារៈ "មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ" ("leave no-one behind") ។

## ៣.៣ ការបឺតស្រូបស្បៀង

នៅក្នុងស្ថានភាពបច្ចុប្បន្ននេះ កង្វល់ដែលទាក់ទងនឹងបញ្ហាអាហារូបត្ថម្ភ នៅតែជាបញ្ហាចម្បង ដោយសារចំណុចដៅ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសំខាន់ៗ ស្តីពីការកាត់បន្ថយបញ្ហាអាហារូបត្ថម្ភ មិនទំនងជាអាចសម្រេចបាន។ ករណីដែលគួរយកចិត្តទុកដាក់ ដើម្បីកំណត់អាទិភាពអាហារូបត្ថម្ភ ជាចលករក្នុងការពន្លឿនការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលអាចជំរុញឱ្យសម្រេចគោលដៅនេះសម្រេចបានលឿន។ កិច្ចការនេះនឹងបង្កើតឱ្យមានឥទ្ធិពលវិជ្ជមានទៅលើវិស័យនានាដូចជា៖ អប់រំ សុខាភិបាល និងកម្លាំងពលកម្មដែលមានផលិតភាព និងមានជំនាញខ្ពស់។ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារអាយុក្រោម៥ឆ្នាំ នៅតែជាបញ្ហានៅឡើយ។ ផ្អែកលើរបាយការណ៍អង្កេតសុខភាព និងប្រជាសាស្ត្រឆ្នាំ២០១៤ របស់ក្រសួងផែនការ កុមារអាយុក្រោម៥ឆ្នាំ៣២%មានភាពក្រិសក្រិន ២៤% មិនគ្រប់ទម្ងន់ ១០%ស្គមស្គាំង។ នេះជាអត្រាមួយខ្ពស់ធៀបនឹងអ្វីដែលបានប្រមើលនៅក្នុងចំណុចដៅ២.២ នៃគោលដៅទី២នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG 2) និងខ្ពស់ជាងប្រទេសដទៃទៀតដែលមានប្រាក់ចំណូលមធ្យមដូចគ្នា។ ប្រមាណ៤៥% នៃ២៦៦លានដុល្លា ដែលជាបន្ទុកប្រចាំឆ្នាំមកលើសេដ្ឋកិច្ច ដោយសារតែបញ្ហាអាហារូបត្ថម្ភ ត្រូវបានប៉ាន់ស្មានថាកើតឡើងដោយសារតែបញ្ហា ក្រិសក្រិន ក្នុងនោះតិចជាង៣% មានការពាក់ព័ន្ធនឹងបញ្ហាអាហារូបត្ថម្ភស្រួចស្រាវ។ បន្ទុកលើសេដ្ឋកិច្ចបណ្តាលពីបញ្ហាក្រិសក្រិនបានបង្ហាញឱ្យឃើញយ៉ាងជាក់ស្តែង ហើយការបន្តកិច្ចប្រឹងប្រែងដើម្បីព្យាបាលករណីស្គមស្គាំងនៅតែមានសារៈសំខាន់ជាសារវន្ត ដោយសារមានភស្តុតាងបង្ហាញថា បញ្ហានេះអាចបង្កផលប៉ះពាល់អវិជ្ជមានមកលើការលូតលាស់ និងការអភិវឌ្ឍរបស់កុមារ។ ដោយសារបញ្ហាក្រិសក្រិន និងស្គមស្គាំង មានកត្តាហានិភ័យរួមគ្នាជាច្រើន ដូច្នេះកិច្ចប្រឹងប្រែងខាងគោលនយោបាយ អាចសម្រួលឱ្យមានចំណងទាក់ទងឆ្ពោះទៅការបង្កើត កម្មវិធីដែលកាន់តែមានលក្ខណៈចម្រុះជាងមុន (NIS etal., 2014; NMCHC, 2016; CARD et al., 2013)។ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែង និងការជំរុញសកម្មភាពឱ្យខ្លាំងក្លាជាងមុន ក្នុងការដោះស្រាយបញ្ហាដែលមានជាយូរនៃបញ្ហាអាហារូបត្ថម្ភនោះទេ នឹងមានហានិភ័យដែលធ្វើឱ្យចំណុចដៅសំខាន់ៗ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDGs សម្រាប់កាត់បន្ថយបញ្ហាអាហារូបត្ថម្ភ នឹងមិនអាចសម្រេចបានឡើយ។

"...នឹងមានហានិភ័យដែលធ្វើឲ្យចំណុចដៅសំខាន់ៗនៃ SDGs សម្រាប់កាត់បន្ថយបញ្ហាអាហារូបត្ថម្ភ នឹងមិនអាចសម្រេចបានឡើយ..."

អាហារូបត្ថម្ភ និងអាកប្បកិរិយារបស់ម្តាយ កង្វះជីវជាតិ និងសារធាតុរ៉ែ ក៏ដូចជាការប្រឈមក្នុងការទទួលបានស្បៀងអាហារគ្រប់គ្រាន់ អាចប៉ះពាល់ជាអវិជ្ជមានមកលើស្ថានភាពអាហារូបត្ថម្ភរបស់កូន។

## អាហារូបត្ថម្ភជាចលករក្នុងការពន្លឿនការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

អាហារូបត្ថម្ភប្រសើរមានសារៈសំខាន់ណាស់ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)មួយចំនួន ហើយ គោលដៅSDGs ជាច្រើនមានឥទ្ធិពលទៅលើសន្តិសុខអាហារូបត្ថម្ភ។ ហេតុដូច្នេះ អាហារូបត្ថម្ភមានទំនាក់ទំនងជាមួយនឹងគោលដៅ និងសូចនាករដទៃទៀត ក្រៅពីគោលដៅទី២ ដែលដោះស្រាយបញ្ហាភាពអត់ឃ្លាន។ ចាំបាច់ត្រូវមានអភិក្រមសន្តិសុខអាហារូបត្ថម្ភពហុវិស័យមួយដើម្បីធានាបានក្នុងការសម្រេចគោលដៅប្រកបដោយភាពជោគជ័យ (SUN-CSA, 2017)។

ការបង្កើនការយកចិត្តទុកដាក់ចំពោះអាហារូបត្ថម្ភ នឹងជំរុញឱ្យគ្រប់សកម្មភាពទាំងអស់បានរួមចំណែកដោយផ្ទាល់ ឬដោយប្រយោលក្នុងការសម្រេចបាននូវគោលដៅអាហារូបត្ថម្ភ ដែលនឹងជួយឱ្យសម្រេចបាននូវគោលដៅទី២ ក៏ដូចជាគោលដៅដទៃផងដែរ។




អាហារូបត្ថម្ភជាកត្តាសំខាន់ក្នុងការសម្រេចបាននូវគ្រប់
គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SUN-SCN, 2017)

តម្រូវការខ្ពស់ខាងអាហារូបត្ថម្ភក្នុងពេលមានផ្ទៃពោះក៏ធ្វើឱ្យស្ត្រីដែលមានផ្ទៃពោះងាយរងគ្រោះ ដោយសារស្ថានភាពអាហារូបត្ថម្ភមិនគ្រប់គ្រាន់ផងដែរ។ ទិន្នន័យបង្ហាញថានៅក្នុងរយៈពេលធម្មតាស្ត្រីមិនសូវបរិភោគរបបអាហារចម្រុះឡើយ ហើយមានការកែលម្អត្រឹមតិចតួច ក្រោយពេលមានផ្ទៃពោះ (NMCHC, 2016; WFP, 2017d)។ បច្ចុប្បន្ននេះ គោលដៅនៃយុទ្ធសាស្ត្រជាតិស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រាប់បញ្ហាអាហារូបត្ថម្ភ ក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ (WRA) មិនស្ថិតក្នុងលំនាំសមស្របឡើយ ដោយមានប្រេវ៉ាឡង់ ១៤% នៃបញ្ហាអាហារូបត្ថម្ភនៅឆ្នាំ២០១៤ ដែលខ្ពស់ជាងចំណុចដៅ ៨%សម្រាប់ឆ្នាំ២០១៥។ រោគស្លេកស្លាំងក៏នៅតែមានអត្រាខ្ពស់ជាប្រចាំផងដែរដែលមានអត្រាមធ្យម៤៥%ក្នុងចំណោមស្ត្រី និង៥៦%ក្នុងចំណោមកុមារ។ យោងតាម របាយការណ៍ស្តីពីអាហារូបត្ថម្ភពិភពលោក ឆ្នាំ២០១៦ កម្ពុជាស្ថិតក្នុងលំដាប់ទី១៦០ក្នុងចំណោម១៨៥ប្រទេសដែលស្ត្រីក្នុងវ័យបន្តពូជមានអត្រាស្លេកស្លាំងខ្ពស់ជាងគេ ដែលជាប់ទាក់ទងនឹងសរីរវិទ្យា ជាងសុខភាពនិងរបបអាហារ ដូច្នេះដំណោះស្រាយដែលមានសក្តានុពល នៅតែមិនទាន់ច្បាស់លាស់នៅឡើយនៅកម្ពុជា (IFPRI, 2016; NIS et al., 2001, 2015; WFP, 2017d; MPDI, 2016)។

វិសមធម៌ខាងសេដ្ឋកិច្ចសង្គម និងការទទួលបានសេវាជាមូលដ្ឋាន ដូចជា សុខភាព ទឹកស្អាត និងអនាម័យ និងការអប់រំ ជាកត្តារួមចំណែកធ្វើឱ្យមានបញ្ហាអាហារូបត្ថម្ភ (NMCHC, 2016)។ ទោះបីការទទួលបានទឹកស្អាត និងលើកកម្ពស់អនាម័យត្រូវបានកែលម្អហើយក៏ដោយ ជាមួយសមាមាត្រនៃប្រជាជនដែលប្រើប្រាស់ប្រភពទឹកស្អាតប្រសើរជាងមុន ដែលកើនឡើងពីប្រមាណ២៣% នៅឆ្នាំ ១៩៩០ ដល់ ៧៥,៥%នៅឆ្នាំ២០១៥ និងសមាមាត្រប្រជាជនដែលទទួលបានការលើកកម្ពស់អនាម័យ ពី ២,៩% ដល់ ៤២% នៅក្នុងអំឡុងពេលដូចគ្នានេះ ទម្លាប់អនុវត្តខាងអនាម័យ នៅតែត្រូវការឱ្យមានការកែលម្អ ដើម្បីឱ្យស្របទៅតាមស្តង់ដារនៃប្រទេសដែលមានស្ថានភាពប្រាក់ចំណូលមធ្យមកម្រិតទាប(WHO&UNICEF, 2015; World Bank, 2017)។

លើសពីនេះ គន្លឹះក្នុងការពង្រឹងការវិនិយោគលើមូលធនមនុស្សគឺតាមរយៈអាហារូបត្ថម្ភក៏ដូចជាការអប់រំផងដែរ។ បញ្ហាអាហារូបត្ថម្ភ អាចប៉ះពាល់ដល់ការសិក្សារបស់សិស្សនិងធ្វើឱ្យលទ្ធផលការងារធ្លាក់ចុះក៏ដូចជាបន្ថែមបន្ទុកលើវិស័យសុខាភិបាលផងដែរ ចំណែកការវិនិយោគលើវិស័យអប់រំអាចពង្រីកការយល់ដឹង និងកែលម្អទម្លាប់អវិជ្ជមាន (CARD et al., 2013)។

កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពជាវិជ្ជមាន លើការលើកកម្ពស់ការចូលរៀននៅថ្នាក់បឋមសិក្សាជាពិសេសនៅតាមទីជនបទ ក្នុងនោះអត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សា បានកើនពី៨១% នៅឆ្នាំ២០០១ ដល់៩៨,៤%នៅឆ្នាំ២០១៥។ គុណភាពនៃការអប់រំ ទាមទារឱ្យមានការកែលម្អដូចដែលបានរកឃើញតាមរយៈលទ្ធផលទាបនៃការសិក្សា ដែលក្នុងនោះសិស្សថ្នាក់ទី៦ ប្រមាណ៣៩% ត្រូវបានរកឃើញថាចំណេះដឹងក្នុងការអានភាសាខ្មែរនៅមានកម្រិតទាបជាងមូលដ្ឋានកំណត់ (MoEYS, 2015)។ ចំនួនម៉ោងរៀនតិច ធៀបនឹងក្រុមសិស្សដូចគ្នាដទៃទៀត និងចំនួនមិនគ្រប់គ្រាន់នៃគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាល ទាមទារឱ្យមានការដោះស្រាយ។ ទន្ទឹមនឹងនេះក៏មានអត្រាខ្ពស់ផងដែរនៃសិស្សរៀនត្រួតថ្នាក់ប្រមាណ ១០% នៅកម្រិតបឋមសិក្សា និង ២០% នៅកម្រិតមធ្យមសិក្សាបឋមភូមិ ទោះបីបញ្ហានេះច្រើនតែជាអត្រាដែលនៅថេរប្រចាំឆ្នាំក៏ដោយ ហើយអត្រាសិស្សមករៀន និងករណីអវត្តមានគឺជាការព្រួយបារម្ភមួយ។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងបង្កើនថវិកាជាតិសម្រាប់វិស័យអប់រំ ដោយផ្តោតលើការជ្រើសរើស ការបណ្តុះបណ្តាល និងការរក្សាក្របខ័ណ្ឌសម្រាប់គ្រូបង្រៀន។

## ៣.៤ ស្ថិរភាពស្បៀង

នៅមានការប្រឈមនៅក្នុងការរក្សា ឬបន្តកំណែលម្អលើការទទួលបានស្បៀង និងការបឹតស្រូបស្បៀង ដោយសារមានប្រជាជនជាច្រើននៅតែងាយរងគ្រោះនៅចំពោះមុខហានិភ័យតាមរដូវកាលដែលអាចធ្វើឱ្យរាំងស្ទះដល់កំណើនវិជ្ជមានទាំងនេះ។ កៅសិបភាគរយនៃជនក្រីក្រកម្ពុជា រស់នៅតាមទីជនបទ នឹងនៅតែងាយរងគ្រោះចំពោះមុខហានិភ័យនៃរបរចិញ្ចឹមជីវិត និងអាកាសធាតុ។ ពាក់ព័ន្ធនឹងប្រជាពលរដ្ឋដែល រស់នៅលើបន្ទាត់ភាពក្រីក្រ ធនាគារពិភពលោកបានរកឃើញថា នៅឆ្នាំ២០១១ វិបត្តិដែលបណ្តាលឱ្យពួកគេខាតបង់ប្រាក់ ១.២០០ រៀលក្នុងមួយថ្ងៃអាចបណ្តាលឱ្យពួកគេមានភាពក្រីក្រ ដែលបណ្តាលឱ្យមានកំណើនភាពក្រីក្រមានភាពទ្វេដង ក្នុងអំឡុងពេលនោះ" (World Bank, 2013)។

របកគំហើញពីការសិក្សាមួយស្តីពី ផលប៉ះពាល់នៃគ្រោះរាំងស្ងួតបណ្តាលពីបាតុភូតអែលនីញ៉ូនៅឆ្នាំ២០១៥-២០១៦ (FAO et al., 2016) បង្ហាញថា ៣៧% នៃគ្រួសារដែលបានអង្កេត បានរាយការណ៍អំពីការខ្វះទឹក ជាមួយការឡើងថ្លៃទឹក ដែលដាក់សម្ពាធក្នុងកម្រិតវិសមាមាត្រមកលើហិរញ្ញវត្ថុនៃគ្រួសារក្រីក្រ។ ការបាត់បង់ផលដំណាំដោយសារតែគ្រោះរាំងស្ងួត នាំឱ្យថយចុះ២២%នៃផលស្រូវ និងផលដំឡូងមីប្រចាំគ្រួសារ និងជាផលវិបាក ៦២% នៃគ្រួសារទាំងនេះ បានរាយការណ៍អំពីការបាត់បង់ប្រាក់ចំណូលក្នុងរយៈពេលមួយឆ្នាំចុងក្រោយ ជាមួយការបាត់បង់ប្រាក់ចំណូលជាមធ្យម១៩% ក្នុងគ្រួសារនីមួយៗ ដែលជាការបាត់បង់ 0,១៩ដុល្លា ក្នុងមនុស្សម្នាក់ៗ នៅក្នុងមួយថ្ងៃសម្រាប់អ្នកជិតក្រ។ ការប៉ុនប៉ងដើម្បីកាត់បន្ថយការបាត់បង់បែបនេះ តម្រូវឱ្យគ្រួសារនានាខ្ចីប្រាក់ជាបន្ថែម ជាមធ្យម១.២៨២ដុល្លាក្នុងមួយគ្រួសារ ដែលជាការបន្ថែមទៅលើនិន្នាការកើនឡើងនៃការជាប់បំណុល ក្នុងចំណោមគ្រួសារក្រីក្រ។ ទោះបីការស្រាវជ្រាវនេះ សន្និដ្ឋានថាការខ្ចីបុលអាចជួយគ្រួសារនានាដែលស្ថិតក្នុងភាពក្រីក្រ នឹង/ឬងាយរងគ្រោះស្រាប់ហើយក៏ដោយ នៅក្នុងរយៈពេលខ្លី វាក៏នាំមកនូវកង្វល់អំពីនិរន្តរភាពនៃកំណើនក្នុងការកាត់បន្ថយភាពក្រីក្រជាបន្តបន្ទាប់ផងដែរ (UNDP, 2017)។ វិបត្តិ ដូចជាបណ្តាលពីបាតុភូតអែលនីញ៉ូ ក៏បានបង្កផលប៉ះពាល់អវិជ្ជមានមកលើភាពចម្រុះនៃរបបអាហាររបស់គ្រួសារនានាផងដែរ ដែលបានថយចុះជាខ្លាំងមកត្រឹម១២%នៃគ្រួសារដែលខ្វះភាពចម្រុះក្នុងរបបអាហារនៅឆ្នាំ២០១៤ ឱ្យកើនឡើងវិញ ដល់១៨% នៅឆ្នាំ២០១៦។ ទិន្នន័យពីការវិភាគភាពងាយរងគ្រោះ ក៏បានគូសបញ្ជាក់ពីការប្រឈមនៃវិបត្តិលើពិភពលោកផងដែរ ដូចជា វិបត្តិហិរញ្ញវត្ថុពិភពលោក និងថ្លៃទំនិញ។ វិបត្តិទាំងនេះរួមគ្នា ក៏បានរួមចំណែកធ្វើឱ្យភាពស្គមស្គាំង បានកើនឡើងពី ៨% ដល់ ១១% នៅរវាងឆ្នាំ ២០០៥ និង ២០១០ (NIS et al., 2011, 2015; UNDP, 2017)។

ទីបំផុត ក្នុងពេលដែលមានការគាំទ្រមោះមុតឱ្យមានវិធានចម្រុះដើម្បីដោះស្រាយបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ របកគំហើញពីការពិគ្រោះយោបល់ជាបន្តបន្ទាប់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (CARD, 2017b, 2017c) បង្ហាញពីតម្រូវការឱ្យមានការពង្រឹងជាបន្ថែម នូវការរៀបចំស្ថាប័នដើម្បីអនុវត្តយុទ្ធសាស្ត្រជាតិស្តីពី សន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមរយៈអភិក្រមពហុវិស័យដែលរួមមាន៖ (១) ការពង្រឹងការផ្តល់អាទិភាព និងការកំណត់លំដាប់លំដោយសកម្មភាពជាអាទិភាពបច្ចុប្បន្នចំនួន៦៤ និងសូចនាករច្រើនជាង១២០ (២) ការពង្រឹងទំនាក់ទំនងជាមួយថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យមានការអនុវត្តនៅតាមមូលដ្ឋាន (៣) ការធានាឱ្យមានកំណើនមូលនិធិនៅមូលដ្ឋាន ដើម្បីធានាថាអាទិភាពនានាបានទទួលធនធានសម្រាប់ការអនុវត្តដោយនិរន្តរភាព និង (៤) ប្តូរការយកចិត្តទុកដាក់លើសមិទ្ធផល ទៅរកលទ្ធផលសម្រាប់រយៈពេលវែង ប្រសើរជាងការយកចិត្តទុកដាក់តែលើសកម្មភាព និងលទ្ធផលរយៈពេលខ្លី។ បញ្ហាទាំងនេះមានអធិប្បាយនៅក្នុងជំពូកទី៦។

# ៤. បញ្ហានានាដែលលេចឡើងថ្មី

ដូចជាការព្រួយបារម្ភបច្ចុប្បន្នផងដែរ បញ្ហានិងកាលានុវត្តិភាពថ្មីៗមួយចំនួនផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភ កំពុងលេចឡើង ដែលទាក់ទងជាមួយការប្រែប្រួលខាងសេដ្ឋកិច្ច សង្គម និងអាកាសធាតុ ដែលកើតឡើងនៅក្នុងប្រទេស។ កម្លាំងជំរុញកំណើនសេដ្ឋកិច្ចមកទល់សព្វថ្ងៃនេះ បានប្រមូលផ្តុំលើការនាំចេញផលិតផល និងសេវាកម្ម ជាពិសេស សម្លៀកបំពាក់ និងទេសចរណ៍។ កំណើននៃការនាំចេញ កើតឡើងដោយសារការងារដែលមានជំនាញនិងចំណាយកម្លាំងពលកម្មទាប និងចំណាកស្រុកដែលធ្វើឱ្យមានការប្រែប្រួលឆាប់រហ័សពីកម្រិតមូលដ្ឋានទាបមួយ។ នៅក្នុងការឈានទៅមុខ កម្ពុជាមានកាលានុវត្តិភាពដែលពឹងផ្អែកលើកំណើននេះ។ ចំពោះហានិភ័យ កត្តាជំរុញទាំងនេះអាចពុំមានលទ្ធភាពធ្វើឱ្យមានកំណើនខ្លាំង ឬ ការកាត់បន្ថយភាពក្រីក្រឡើយ ផ្ទុយទៅវិញវាទាមទារឱ្យមានការវិនិយោគច្រើនជាងមុនលើមូលធនមនុស្ស ដែលរួមទាំងការផ្តោតជាពិសេសលើអាហារូបត្ថម្ភ ដើម្បីរក្សាផលិតភាពនិងភាពប្រកួតប្រជែង (World Bank, 2017; WFP, 2017b)។ ការកើនឡើងនៃកម្រៃពលកម្ម ក៏បានធ្វើឱ្យប៉ះពាល់ដល់ចំណងទាក់ទងយ៉ាងរឹងមាំតាមប្រពៃណីរវាងគ្រួសារ និងផលិតកម្មស្បៀងដោយខ្លួនឯងផងដែរ។ ទាក់ទងនឹងចំណុចនេះ គេចាំបាច់ត្រូវមានដំណោះស្រាយ ចំពោះវិសមភាពដែលកំហិតលើការទទួលបានស្បៀង ក៏ដូចជា ការប្រឈមក្នុងការបឺតស្រូបស្បៀងផងដែរ ទើបអាចដោះស្រាយឬសគល់នៃភាពក្រីក្រ និងភាពងាយរងគ្រោះទៅបាន។

"...មានកាលានុវត្តិភាព ដែលផ្អែកលើកំណើននេះ។ ចំពោះហានិភ័យ កត្តាជំរុញទាំងនេះអាចពុំមានលទ្ធភាពធ្វើឲ្យមានកំណើនខ្លាំង ឬការកាត់បន្ថយភាពក្រីក្រឡើយ ផ្ទុយទៅវិញវាទាមទារឲ្យមានការវិនិយោគច្រើនជាងមុនលើមូលធនមនុស្ស..."

ចំណាកស្រុកពីជនបទមកទីក្រុងមាន៥៦% នៃចំណាកស្រុកសរុប ដែលភាគច្រើនចូលមកភ្នំពេញ និងបានកើតឡើងជាពិសេស ដោយសារកត្តាសេដ្ឋកិច្ច ដែលបានជួយសម្រួលឱ្យមានកំណើន និងការកាត់បន្ថយភាពក្រីក្រ (UNDP, 2017; WFP, 2017a)។ ទោះជាយ៉ាងណាក៏ដោយ ការរីកចម្រើនយ៉ាងរហ័សនៃនគរូបនីយកម្ម ក៏បានធ្វើឱ្យមានកំណើនប្រជាជនក្រីក្រនៅតំបន់ជាយក្រុង និងធ្វើឱ្យចំនួនប្រជាជននៅតំបន់ទីក្រុងមានការកើនឡើង និងធ្វើឱ្យមានគន្លាតរវាងអ្នកមាននិងអ្នកក្រីក្រ។ ចំពោះអ្នកដែលរស់នៅតាមជាយក្រុងទាំងនេះ ការទទួលបានទឹកស្អាត និងអនាម័យ និងមធ្យោបាយថែរក្សាសុខភាព នៅតែជាឧបសគ្គ ទោះបីជាស្ថានភាពរបស់ពួកគាត់ប្រសើរជាងអ្នករស់នៅជនបទក៏ដោយ។ នៅពេលដែលល្បឿននៃនគរូបនីយកម្មបន្តរីកដុះដាល ស្ថានភាពនេះត្រូវបានរំពឹងថានឹងនាំមកនូវបន្ទុកកាន់តែច្រើនឡើងមកលើការទទួលបានសេវាកម្ម ដែលលំបាករួចទៅហើយ (WFP, 2017a; UNFPA, 2014)។ ការវាស់វែងសុខុមាលភាព និង/ឬ ភាពក្រីក្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដូចជា ការប្រើប្រាស់សន្ទស្សន៍ភាពក្រីក្រដោយកត្តាចម្រុះច្រើនយ៉ាង (MPI) អាចបង្ហាញថាមានប្រយោជន៍ សម្រាប់អ្នករៀបចំគោលនយោបាយទៅអនាគត ដោយហេតុថា បច្ចុប្បន្ននេះ ភាពក្រីក្រខាងប្រាក់ចំណូល បានឈានដល់កម្រិតទាបពុំធ្លាប់មានពីមុនមក ប៉ុន្តែភាពងាយរងគ្រោះនៅតែជាហានិភ័យមួយ។

កម្ពុជាត្រូវបានគេមើលឃើញថាមានការប្រែប្រួលរបបអាហារ ឆ្ពោះទៅរកការបរិភោគអាហារឆ្អិនស្រាប់ ដែលជានិន្នាការឆ្ពោះទៅរករោគធាត់កាន់តែច្រើនឡើង ជាពិសេសក្នុងចំណោមស្ត្រី និងបង្កើនហានិភ័យនៃជំងឺមិនឆ្លង(NCDs)។ នៅក្នុងគោលដៅនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ សម្រាប់ការលើសអាហារូបត្ថម្ភក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ (WRA) មានចំណុចដៅ១២% សម្រាប់ឆ្នាំ២០១៨ ទោះបីតួលេខនេះមានដល់១៨% នៅឆ្នាំ២០១៤ក៏ដោយ (NIS et al., 2001, 2015; NMCHC, 2016)។ នគរូបនីយកម្មក៏បាននាំមកនូវផលវិបាកអវិជ្ជមានខ្លះៗសម្រាប់

សុខុមាលភាពកុមារលើផ្នែកអាហារូបត្ថម្ភផងដែរ ការបំបៅដោះកូនតែមួយមុខ មានអត្រាទាបនៅភ្នំពេញ (៧៧%)។ បរិស្ថានទីប្រជុំជនខ្លះ ដូចជារោងចក្រកាត់ដេរ ដែលអាចពុំមានក្របខ័ណ្ឌច្បាប់ ឬសម្បទាអំណោយផលអាចផ្តល់ឱកាសសម្រាប់ពង្រីកការយល់ដឹង និងការអនុវត្តលើបញ្ហាអាហារូបត្ថម្ភនិងសុខភាពក្នុងចំណោមក្រុមមនុស្សជាច្រើន។

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ បានបង្កការប៉ះពាល់អវិជ្ជមានមកលើសន្តិសុខស្បៀង និង អាហារូបត្ថម្ភ។ មានការរំពឹងថា តាមអត្រាបច្ចុប្បន្ន ល្បឿននៃការប្រែប្រួលអាកាសធាតុក្នុងរយៈពេល៤0ឆ្នាំខាងមុខ ទំនងជាលឿនជាងការបន្សាំនៃវិធីសាស្ត្រកសិកម្មនៅមូលដ្ឋាន (IFPRI, 2013)។ កម្ពុជាប្រឈមហានិភ័យកម្រិតខ្ពស់ពីការប៉ះពាល់នៃគ្រោះមហន្តរាយធម្មជាតិ ដែលឈរក្នុងចំណាត់ថ្នាក់ទី៩ លើសន្ទស្សន៍ហានិភ័យពិភពលោក និងក្នុងលំដាប់ទី៤១ ក្នុងចំណោមប្រទេសចំនួន១៧១ ខាងផ្នែកភាពងាយរងគ្រោះ (Garschagen et al., 2016; WFP, 2017b) ដោយមានប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុតរស់នៅជុំវិញបឹងទន្លេសាប។ ហានិភ័យនេះកាន់តែធ្ងន់ធ្ងរ ដោយសារការរេចរឹលជាប្រចាំនៃធនធានធម្មជាតិ។ ការប៉ាន់ស្មានផ្លូវការបង្ហាញថា វិសាលភាពគម្របព្រៃឈើបានធ្លាក់ចុះពីជិត ៦0% នៅឆ្នាំ២00៦ មកត្រឹម ៤៩.៤៨% នៅឆ្នាំ ២០១៤ (RGC, 2015; World Bank, 2017)។

គម្រោងដែលទទួលហិរញ្ញវត្ថុពីប្រភពក្រៅប្រទេស ភាគច្រើនបានគាំទ្រដល់កិច្ចប្រឹងប្រែងឆ្ពោះទៅការអភិវឌ្ឍផ្នែកទន់ និងការកែប្រែអាកប្បកិរិយា នៅក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗនេះ ក្នុងវិស័យនានា ដូចជាទឹកស្អាតនិងអនាម័យ អាហារូបត្ថម្ភ និង បរិស្ថាន ចំណែកការចំណាយហិរញ្ញវត្ថុពីប្រភពក្នុងប្រទេសបានផ្តោតលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន តម្រូវឱ្យមានការផ្លាស់ប្តូរពីជំនួយឥតសំណងទៅរកកម្ចីពីប្រភពខាងក្រៅ ដែលជាផ្នែកមួយនៃការវិវឌ្ឍការផ្តល់ជំនួយអភិវឌ្ឍន៍សម្រាប់កម្ពុជា។ ក្នុងដំណើរឆ្ពោះទៅមុខ ការបង្កើតជម្រើសហិរញ្ញប្បទានពីប្រភពក្នុងប្រទេស និងប្រភពពីក្រៅប្រទេស គួរតែជាជម្រើសដែលត្រូវពិនិត្យមើល ដើម្បីពង្រឹងការចំណាយសំខាន់ៗក្នុងវិស័យសាធារណៈសម្រាប់ការអភិវឌ្ឍប្រកបដោយសមធម៌។

## ៥. យុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

យុទ្ធសាស្ត្រនានា ដែលបានស្នើនៅក្នុងផ្នែកនេះ បានមកពីការវិភាគព័ត៌មានដែលប្រមូលបាន នៅក្នុងការពិនិត្យឯកសារនានាដែលមានស្រាប់ ការសម្ភាសអ្នកពាក់ព័ន្ធសំខាន់ៗ និងការពិគ្រោះយោបល់ជាបន្តបន្ទាប់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (CARD, 2017b, 2017c)។ កិច្ចប្រឹងប្រែងស្របគ្នា ត្រូវបន្តផ្តោតលើផ្នែកជាច្រើន ដើម្បីកែលម្អបន្ថែមទៀត នូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ កិច្ចប្រឹងប្រែងទាំងនេះត្រូវចាត់ជាអាទិភាពនិងរៀបចំតាមលំដាប់លំដោយជាមួយការ ផ្តោតលើកត្តាជំរុញឱ្យមានការកែប្រែ។ កិច្ចខិតខំប្រឹងប្រែងកន្លងមកច្រើនតែបានផ្តោតលើការពង្រឹងភាពមានស្បៀង ដោយសង្កត់ធ្ងន់ជាពិសេសលើផលិតកម្មស្រូវ។ មានភាពចាំបាច់ដើម្បីបង្កើនការផ្តោតលើការលើកកម្ពស់ការទទួលបានស្បៀងតាមរយៈកំណើនដែលកាន់តែមាន សមធម៌ និងជាបរិយាប័ន្ន ក៏ដូចជាការពង្រីកវិធានការគាំពារសង្គម និងពង្រឹងការបឺតស្រូបស្បៀងផងដែរ តាមរយៈវិធានការបង្កើនអាហារូបត្ថម្ភជាក់លាក់ និងវិធានការដែលគិតគូរអំពីអាហារូបត្ថម្ភ (UNICEF, 2015)។[1]

"មានភាពចាំបាច់ដើម្បីបង្កើនការផ្តោតលើការលើកកម្ពស់ការទទួលបានស្បៀងតាមរយៈកំណើនដែលកាន់តែមានសមធម៌និងជាបរិយាប័ន្ន ក៏ដូចជាការពង្រីកវិធានការគាំពារសង្គម និងពង្រឹងការបឺតស្រូបស្បៀងផងដែរ តាមរយៈវិធានការពង្រីកអាហារូបត្ថម្ភជាក់លាក់ និងវិធានការដែលគិតគូរអំពីអាហារូបត្ថម្ភ..."

វិធានការទាំងនេះនឹងមានតួនាទីជា កត្តាជំរុញដើម្បីឱ្យមានការកែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ ដើម្បីសម្រួលឱ្យមានការកែប្រែបែបនេះកិច្ចប្រឹងប្រែងនានាដែលទាក់ទងនឹងភាពមានស្បៀងត្រូវតែឈានឆ្ពោះទៅរកការបង្កើនភាពចម្រុះ និងគុណភាពស្បៀង និងកសិកម្មដែលគិតគូរអំពីអាហារូបត្ថម្ភ។ ក្នុងពេលដែលបរិបទនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ បច្ចុប្បន្ន នឹងបន្តស្ថិតក្រោមឥទ្ធិពលនៃក្របខ័ណ្ឌសន្តិសុខស្បៀង ក្នុងដំណើរឆ្ពោះទៅមុខ ក្របខ័ណ្ឌកែសម្រួលមួយដែលឆ្លុះបញ្ចាំងអំពីគំរូថ្មីមួយត្រូវបានស្នើឡើងសម្រាប់ការពិចារណា។ ដើម្បីធានាឱ្យមានយុទ្ធសាស្ត្រជាតិមួយដែលផ្តោតចំគោលដៅបានច្រើនជាងមុន ការយកចិត្តទុកដាក់ គួរតែផ្តោតលើការឈានទៅរកប្រធានបទអន្តរវិស័យជាអាទិភាពដែលបន្ថែមតម្លៃ ដោយនាំយកអ្នកពាក់ព័ន្ធសំខាន់ៗ មកធ្វើការជាមួយគ្នា ចំណែកយុទ្ធសាស្ត្ររបស់ក្រសួងពាក់ព័ន្ធនានា អាចផ្តោតលើការជំរុញវិស័យការងារជាក់លាក់។ ការពង្រឹងការរៀបចំស្ថាប័ន និងការកសាងសមត្ថភាព សម្រាប់កែលម្អសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ចាំបាច់ត្រូវគូសបញ្ជាក់ពីចំណុចទាំងនេះ។

---

1 *«អន្តរាគមន៍អាហារូបត្ថម្ភជាក់លាក់ ដោះស្រាយមូលហេតុចំពោះមុខនៃបញ្ហាអាហារូបត្ថម្ភ ដូចជារបបអាហារមិនគ្រប់គ្រាន់ និងមូលហេតុជាឫសគល់ខ្លះៗ ដូចជា ទម្លាប់ក្នុងការបរិភោគ និងការទទួលបានចំណីអាហារ។ អន្តរាគមន៍ដែលគិតគូរអំពីអាហារូបត្ថម្ភ អាចដោះស្រាយមូលហេតុជាឫសគល់ខ្លះៗនៃបញ្ហាអាហារូបត្ថម្ភ ដោយរួមបញ្ចូលគោលដៅអាហារូបត្ថម្ភ និងសកម្មភាពក្នុងវិស័យខុសៗគ្នាជាច្រើន។ អន្តរាគមន៍នេះក៏អាចមាននាទីជាវេទិកាសម្រាប់ការផ្តល់អន្តរាគមន៍អាហារូបត្ថម្ភជាក់លាក់ផងដែរ។»*

## ៥.១ ភាពមានស្បៀង៖ ពង្រីកការផ្តោតលើកសិកម្មដែលមានគុណភាពខ្ពស់ ចម្រុះ ធន់ និងគិតគូរពីអាហារូបត្ថម្ភ

### គោលដៅរង

២.៣ ត្រឹមឆ្នាំ២០៣០ ទទួលបានកំណើនទ្វេដងនៃផលិតផលកសិកម្ម និងចំណូលរបស់ផលិតកររុនតូច ជាពិសេសស្ត្រី ជនជាតិដើមភាគតិច គ្រួសារកសិករ អ្នកចិញ្ចឹមសត្វ និងអ្នកនេសាទ រួមទាំងតាមរយៈការធានា និងការទទួលបាននូវសមភាពដីធ្លី ធនធាន និងធាតុចូលសម្រាប់ផលិតកម្មដទៃទៀត ចំណេះដឹង សេវាហិរញ្ញវត្ថុ ទីផ្សារ និងកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម និងការងារក្នុងផ្នែកមិនមែនកសិកម្ម។

### ការពិចារណាជាយុទ្ធសាស្ត្រសម្រាប់កម្ពុជា

» ធ្វើពិពិធកម្មផលិតកម្មកសិកម្ម - បង្កើនផលិតកម្មអាហារសម្បូរជីវជាតិ
» កែលម្អសង្វាក់តម្លៃផលិតកម្ម និងការកែច្នៃ - រួមបញ្ចូលទាំងការបញ្ចូលមីក្រូសារជាតិក្នុងអាហារ
» បង្កើនគុណភាព និងសុវត្ថិភាពម្ហូបអាហារ (នាំចូល នាំចេញ និងទីផ្សារក្នុងស្រុក)
» លើកកម្ពស់បច្ចេកទេសកសិកម្មដែលមានប្រសិទ្ធភាព ផ្តល់តម្លៃបន្ថែម និងមានចីរភាព
» បង្កើនភាពមានស្បៀង ស្ថិរភាពស្បៀង និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធាន
» ត្រួតពិនិត្យមើលឡើងវិញអំពីការផ្តោតលើការនាំចេញ រួមទាំងលក្ខណៈសម្បត្តិក្នុងការប្រកួតប្រជែង

ផ្អែកលើការរីកចម្រើនដែលសម្រេចបានលើវិស័យកសិកម្ម នៅក្នុងអាយុកាលនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភបច្ចុប្បន្ន ការសង្កត់ធ្ងន់លើដំណើរការឈានទៅមុខ ទាមទារឱ្យកែប្រែការយកចិត្តទុកដាក់លើការបង្កើនផលិតកម្មពីបរិមាណ ទៅរកគុណភាព ជាមួយការពង្រីកភាពចម្រុះនៃផលិតកម្ម ទៅរកស្បៀងអាហារដែលសម្បូរជីវជាតិ និងឆ្ពោះទៅ កសិកម្មដែលគិតគូរពីអាហារូបត្ថម្ភ។ ពិពិធកម្ម និងការបង្កើនគុណភាពអាចបង្កើនប្រាក់ចំណូលក្នុងចំណោមកសិករខ្នាតតូច បង្កើនភាពធន់ទៅនឹងវិបត្តិនានា និងបង្កើនការទទួលបានស្បៀង។ ទន្ទឹមនឹងនេះ ពិពិធកម្មនឹងកែលម្អអាហារូបត្ថម្ភ សម្រាប់ប្រជាជនជាទូទៅ ដោយបង្កើន ផលិតផលដែលសម្បូរមីក្រូសារធាតុចិញ្ចឹម។ ការកែលម្អគុណភាព និងសុវត្ថិភាពស្បៀង (ទាំងក្នុងវិស័យកសិកម្ម និងឧស្សាហកម្មចំណីអាហារ) នឹងត្រូវការឱ្យមានជាចាំបាច់ ដើម្បីគាំទ្រដល់ការប្រែប្រួលទាំងនេះ។ ចំណុចទាំងនេះ គឺជាផ្នែករួមនៃកសិកម្មដែលគិតគូរអំពីអាហារូបត្ថម្ភ ដែលដោះស្រាយ មូលហេតុជាឫសគល់នៃបញ្ហាអាហារូបត្ថម្ភដោយផ្តល់ការគាំទ្រដល់ភាពមានស្បៀង ការទទួលបានស្បៀង និងការបឺតស្រូបស្បៀងអាហារចម្រុះ ដែលមានសុវត្ថិភាព និងមានជីវជាតិខ្ពស់ ទន្ទឹមនឹងផ្តល់ប្រាក់ចំណូល និងធនធានសម្រាប់អ្នកផលិតព្រមទាំងគាំទ្រចំពោះសុខភាពមនុស្ស និងបរិស្ថានដែលរួមទាំង សម្រួលឱ្យមានពេលវេលាសម្រាប់ការថែរទាំផងដែរ។

> "...ទាមទារឲ្យកែប្រែការយកចិត្តទុកដាក់លើការបង្កើនផលិតកម្មពីបរិមាណ ទៅរកគុណភាព ជាមួយការពង្រីកភាពចម្រុះនៃផលិតកម្ម ទៅរកស្បៀងអាហារដែលសម្បូរជីវជាតិ និងឆ្ពោះទៅកសិកម្មដែលគិតគូរពីអាហារូបត្ថម្ភ..."

ការកែលម្អខ្សែសង្វាក់តម្លៃ ដែលរួមទាំងការពង្រីកលទ្ធភាពរក្សាទុក ក្រោយពេលប្រមូលផល ការកែច្នៃ និងកិច្ចប្រឹងប្រែង បញ្ចូលមីក្រូសារជាតិនានា និងការជំរុញបច្ចេកទេសកសិកម្ម ដែលផ្តល់ប្រសិទ្ធផលកាន់តែខ្ពស់ ដែលបន្ថែមតម្លៃនិងនិរន្តរភាពព្រមទាំងប្រព័ន្ធស្បៀងផងដែរ (RGC, 2016) នឹងសម្រួលឱ្យមានផលិតកម្មនៃផលិតផល ដែលកាន់តែមានតម្លៃខ្ពស់។ ដើម្បីជួយដល់កិច្ចការនេះ កិច្ចប្រឹងប្រែងត្រូវតែធ្វើឡើង ដើម្បីដោះស្រាយឧបសគ្គ ដែលកសិករប្រឈម ទាក់ទងនឹងលទ្ធភាពទទួលបានឥណទាន បច្ចេកវិទ្យា និងទីផ្សារធំទូលាយ។ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតរួចមកហើយនូវគោលនយោបាយនានាសម្រាប់ផ្តល់

ឥណទានកសិកម្ម និងសេវាផ្សព្វផ្សាយដើម្បីបាន បច្ចេកវិទ្យា និងទម្លាប់អនុវត្តន៍ប្រសើរជាងមុនក្នុង ការដាំដំណាំ ហើយកិច្ចប្រឹងប្រែងក៏កំពុងធ្វើ ផងដែរ ដើម្បីទប់អត្រាការប្រាក់ពីមីក្រូឥណទាន។ វិសាលភាពគ្របដណ្តប់ និងលទ្ធភាពទទួលបាន សេវាផ្សព្វផ្សាយ និងឥណទានរបស់កសិករខ្នាត តូច អាចនឹងពង្រីកបន្ថែមដើម្បីធានាការទទួល បានកាន់តែប្រសើរនូវធាតុចូល ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា។ ការពង្រឹងសហគមន៍អភិវឌ្ឍន៍ កសិកម្ម មានតួនាទីក្នុងការបង្កើតលក្ខខណ្ឌ អំណោយផល សម្រាប់ការទទួលបានធាតុចូល ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាផងដែរ។

កម្រិតខ្ពស់នៃហានិភ័យចំពោះវិបត្តិធម្មជាតិ និងសេដ្ឋកិច្ច តម្រូវឱ្យមានការពង្រឹងភាពធន់នៅ ក្នុងប្រព័ន្ធផលិតកម្ម។ ប្រការនេះអាចសម្រេច បាន តាមរយៈកសិកម្មកាន់តែចម្រុះជាងមុន ការពង្រីកនូវការប្រើប្រាស់ ប្រព័ន្ធតាមដានធាតុ អាកាស តម្លៃទំនិញ និងសន្តិសុខស្បៀង និង អាហារូបត្ថម្ភ ដើម្បីត្រៀមខ្លួនសម្រាប់វិបត្តិនានា ដែលអាចកើតមាន។ ការពិនិត្យមើលឱ្យបាន ទូលំទូលាយ អំពីការផ្តោតលើការនាំចេញនាពេល បច្ចុប្បន្ននេះក៏ដូចជាភាពខ្លាំងរបស់កម្ពុជានៅក្នុង ការផលិត នឹងជួយកម្ពុជាក្នុងការពង្រឹងកសិកម្ម ដែលធន់ទ្រាំ។ ការពង្រឹងយន្តការស្បៀងបម្រុង និង ការទទួលបានឥណទានសម្រាប់គ្រាអាសន្ន នឹងជួយដល់ការត្រៀមលក្ខណៈសម្រាប់កិច្ចប្រឹង ប្រែងឆ្លើយតបបន្ទាន់ ក្នុងករណីចាំបាច់។

ជាចុងក្រោយ ការយកចិត្តទុកដាក់លើការ ពង្រឹងសិទ្ធិអំណាច និងការអប់រំដល់ស្ត្រី គឺជា កិច្ចការរួមមួយ ដើម្បីលើកកម្ពស់កសិកម្មដែល គិតគូរអំពីអាហារូបត្ថម្ភ។ ការស្រាវជ្រាវថ្មីៗនេះ បានគូសបញ្ជាក់ថា ការពង្រឹងសិទ្ធិអំណាច ដល់ស្ត្រី អាចជួយគាំទ្រកសិកម្មដែលគិតគូរអំពី អាហារូបត្ថម្ភ រួមមានតាមរយៈ គ្រួសារដែលមាន ជីវភាពប្រសើរ ទទួលបានផលិតកម្មចម្រុះប្រសើរជាងមុន នៅពេលសិទ្ធិអំណាចរបស់ស្ត្រីត្រូវបានពង្រឹង។ បន្ថែមលើនេះទៀត ភាពចម្រុះនៃផលិតកម្ម ទំនាក់ទំនងជាមួយការកែប្រែឥរិយាបថដែលពាក់ព័ន្ធនឹង អាហារូបត្ថម្ភ ការកើនឡើងនៃជីវភាពរស់នៅ និងរបបអាហារចម្រុះនៅក្នុងសម្រាប់គ្រួសារ។ នៅពេល

## ប្រធានបទទាំង ១០សម្រាប់កសិកម្មដែលគិតគូរអំពីអាហារូបត្ថម្ភ

១. **ការលើកកម្ពស់ពិពិធកម្មប្រព័ន្ធស្បៀង** ដែលសម្បូរសារធាតុចិញ្ចឹម ធន់នឹងអាកាសធាតុ មានតម្លៃផ្នែកសេដ្ឋកិច្ច និងអាចរកបាននិងសមស្រប នៅក្នុងមូលដ្ឋាន និងកសិកម្មចម្រុះដែលរួមទាំង ដំណាំចម្រុះមុខ ការផលិតកម្មសត្វនិងត្រីដើម្បី បង្កើនភាពចម្រុះ។

២. **ផលិតកម្មស្បៀងនៅជុំវិញគេហដ្ឋាន** សម្រាប់កសិករខ្នាតតូច ដើម្បីផលិតស្បៀងគ្រប់ប្រភេទដែលផ្តល់សុខភាពល្អពេញមួយឆ្នាំ។

៣. **ពង្រឹងការទទួលបានទីផ្សារ និងការភ្ជាប់ទំនាក់ទំនង**កសិករតូចតាចទៅនឹងទីផ្សារ។

៤. កម្មវិធីតាមសាលាស្តីពីការផលិត និងការប្រើប្រាស់ស្បៀង ដើម្បីពង្រឹង**ការយល់ដឹងអំពីអាហារូបត្ថម្ភ។**

៥. ពង្រីក**ការយល់ដឹងដល់អ្នកប្រើប្រាស់អំពីអាហារូបត្ថម្ភ និងសុវត្ថិភាពចំណីអាហារ** តាមរយៈការប្រើប្រាស់ស្តង់ដារចំណីអាហារ

៦. **គាំទ្រការលើកកម្ពស់ការយល់ដឹងរបស់មាតា** អំពីអាហារចម្រុះដែលមានសុវត្ថិភាព និងការទទួលបានការថែទាំកុមារ

៧. **ពង្រឹងការអប់រំនិងសិទ្ធអំណាចស្ត្រី** ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី។

៨. **និរន្តរភាពវិស័យជលផល** តាមរយៈ ការកែលំអវារីវប្បកម្មខ្នាតតូច និងការការពារធនធានធម្មជាតិ។

៩. **ពង្រឹងការរក្សាទុក ការស្តុកទុក និងការកែច្នៃ** ដើម្បីរក្សាគុណភាពចំណី ការរក្សាទុកឱ្យបានយូរ និងមានសុវត្ថិភាព

១០. **លើកកម្ពស់កិច្ចសហការរវាងវិស័យកសិកម្ម សុខភាព ទឹកស្អាត និងអនាម័យ** ដើម្បីបង្កើនគុណភាពអាហារូបត្ថម្ភ។

យុទ្ធសាស្រ្តជាតិស្តីពី សន្តិសុខស្បៀង និង អាហារូបត្ថម្ភ និងគោលនយោបាយដែលពាក់ព័ន្ធ យោងទៅបញ្ហាយេនឌ័រ តម្រូវឱ្យមានការវិភាគយេនឌ័រ នៃស្ថានភាពបច្ចុប្បន្នរបស់បុរសស្រ្តី កុមារា និង កុមារី និងការពិចារណាដែលអាចឱ្យមានការចូលរួមរបស់ពួកគេ ក្នុងការធ្វើសេចក្តីសម្រេច ដើម្បីទទួលផលបានពេញលេញ ពីការយកចិត្តទុកដាក់ខាងយេនឌ័រ (FAO, 2017b; WFP, 2017e; MoH, 2014)។

**ភាពធនស្បៀង**

ទាក់ទងនឹងភាពទទួលបានស្បៀង
- កែលម្អជីវភាពរស់នៅរបស់អ្នកក្រ និង កសិករខ្នាតតូចនៅជនបទ

ទាក់ទងនឹងការបឺតស្រូបស្បៀង
- ពង្រីកកសិកម្មដែលគិតគូរពីអាហារូបត្ថម្ភ

ទាក់ទងនឹងស្ថិរភាពស្បៀង
- ពង្រឹងផលិតកម្មស្បៀងនិងប្រព័ន្ធតាមដានតម្លៃ
- លើកកម្ពស់ភាពធន់ក្នុងប្រព័ន្ធផលិតកម្ម
- ពង្រឹងស្បៀងបម្រុងទុក

## យេនឌ័រ និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

ស្រ្តីមានតួនាទីដ៏សំខាន់បំផុតនៅក្នុងប្រព័ន្ធស្បៀង ផលិតកម្ម ការរៀបចំ ការប្រើប្រាស់ និងការបែងចែកស្បៀងអាហារ។ វិសមភាពយេនឌ័រត្រូវបានមើលឃើញច្បាស់តាមរយៈកត្តាដូចជា ស្រ្តី និងកុមារីទទួលបានការអប់រំទាប កង្វះភាពសម្រេចចិត្តផ្នែកសេដ្ឋកិច្ច និងសិទ្ធិអំណាចក្នុងការសម្រេចចិត្ត ទទួលរងទុក្ខនូវផលលំបាកពីការជួញដូរមនុស្ស ចំណាកស្រុក អំពើហឹង្សាយេនឌ័រ និងកង្វះធនធានប្រកបរបរចិញ្ចឹមជីវិត។ វិសមភាពទាំងនេះរួមជាមួយនឹងការមិនបានផ្តល់តម្លៃគ្រប់គ្រាន់ដល់ស្រ្តី គឺជាកត្តារួមចំណែកបង្កប៉ះពាល់ដល់សន្តិសុខស្បៀង។

ដើម្បីលើកកម្ពស់យេនឌ័រឱ្យសមស្របទៅតាមគោលនយោបាយសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គួរមានការវិភាគទៅលើយេនឌ័រ ដើម្បីប្រមូលព័ត៌មានសម្រាប់ដាក់បញ្ចូលក្នុងការរៀបចំគោលនយោបាយ ដែលគួរពិចារណាទៅលើកត្តាខាងក្រោម៖

- ស្វែងយល់អំពីកត្តាសំខាន់ៗដូចជា ច្បាប់ទម្លាប់សង្គមពាក់ព័ន្ធនឹងការសម្រេចចិត្ត ការបែងចែកការងារ និងឥទ្ធិពលនៃការងារពុំមានកម្រៃ
- បង្កើតគោលធៀប និងសូចនាករយេនឌ័រសម្រាប់វាស់វែងទៅលើភាពខុសគ្នានៃការចូលរួម អត្ថប្រយោជន៍ លទ្ធផល និងផលប៉ះពាល់ រវាងស្រ្តី បុរស កុមារី កុមារា ការផ្លាស់ប្តូរទំនាក់ទំនង យេនឌ័រ និង
- ប្រមូលទិន្នន័យតាមភេទ និងអាយុ ដើម្បីស្វែងយល់អំពីភាពខុសគ្នានៃផលប៉ះពាល់ និងបញ្ហា របស់បុរស ស្រ្តី កុមារា និងកុមារី និងដើម្បីស្វែងយល់អំពីឱកាសក្នុងការលើកកម្ពស់ភាពសិទ្ធិអំណាចដល់ស្រ្តី។

ប្រភព៖ WFP (2017e)

# ៥.២ ភាពទទួលបានស្បៀង៖ ពង្រីកភាពទទួលបានស្បៀង (មិនទុកឲ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ)

## គោលដៅរង

២.១ ត្រឹមឆ្នាំ ២០៣០ បញ្ចប់ភាពអត់ឃ្លាននិងធានាថាប្រជាពលរដ្ឋទាំងអស់ ជាពិសេសជនក្រីក្រ និងប្រជាពលរដ្ឋដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ រួមទាំង កុមារទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ នៅគ្រប់រដូវ។

## ការពិចារណាជាយុទ្ធសាស្ត្រសម្រាប់កម្ពុជា

- បង្កើនការយកចិត្តទុកដាក់ចំពោះការទទួលបានស្បៀងអាហារ (មានតំលៃសមរម្យ មានគ្រប់គ្រាន់)
- ដោះស្រាយវិសមភាពក្នុងការទទួលបានស្បៀង - មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ និង គិតគូរទៅលើ ក្រុមប្រជាពលរដ្ឋផ្សេងៗ យេនឌ័រ បំលាស់ប្តូរក្នុងគ្រួសារ
- ពិនិត្យឡើងវិញទៅលើយុទ្ធសាស្ត្រអន្តរាគមន៍ដោយផ្អែកលើភាពងាយរងគ្រោះ
- បង្កើន និងលើកកម្ពស់ការយល់ដឹងនូវជម្រើសចំណីអាហារ - របបអាហារចម្រុះ
- ពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គម និងធានាឱ្យមានទំនាក់ទំនងរវាង សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងការគាំពារសង្គម

ទន្ទឹមនឹងការកែលម្អយ៉ាងទូលំទូលាយលើភាពមានស្បៀង ក៏ត្រូវបង្កើនការយកចិត្តទុកដាក់ពង្រឹងភាពទទួលបានស្បៀងផងដែរជាពិសេសសម្រាប់ជនងាយរងគ្រោះបំផុតស្របជាមួយចំណុចដៅទី១នៃSDG2 **"ត្រឹមឆ្នាំ ២០៣០ បញ្ចប់ភាពអត់ឃ្លាននិងធានាថាប្រជាពលរដ្ឋទាំងអស់ ជាពិសេសជនក្រីក្រ និងប្រជាពលរដ្ឋដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ រួមទាំង កុមារទទួលបានអាហារគ្រប់គ្រាន់ មានសុវត្ថិភាព និងប្រកបដោយអាហារូបត្ថម្ភ នៅគ្រប់រដូវ"** (UN, 2016; RGC, 2016)។ ការទទួលបានអាហារ មិនត្រឹមតែសំដៅលើធនធានដែលចាំបាច់សម្រាប់ទទួលបានអាហារចម្រុះដែលមានតម្លៃសមស្រប ដូចជាតាមរយៈ ឱកាសការងារ និងរបរចិញ្ចឹមជីវិតសមរម្យប៉ុណ្ណោះទេ ប៉ុន្តែវាក៏សំដៅផងដែរចំពោះសិទ្ធិទទួលបានអាហារ យេនឌ័រ និងការធ្វើសេចក្តីសម្រេចអំពីការទទួលបានអាហារ។ ភាពទទួលបានស្បៀង ត្រូវបានយល់ខុសថាជាការពង្រីកបន្ថែមនូវភាពមានស្បៀង ដូច្នេះមានការផ្តល់អនុសាសន៍ថា នៅពេលរៀបចំយុទ្ធសាស្ត្រនាពេលអនាគត ទិដ្ឋភាពនេះត្រូវតែពិចារណាដោយឡែក។ បញ្ហាដែលទាក់ទងនឹងការទទួលបានស្បៀងសម្រាប់គ្រួសារនានា ក៏ដូចជា ភាពចម្រុះនៃរបបអាហារ និងការបឹតស្រូប បច្ចុប្បន្ននេះ បានក្លាយជាបញ្ហាគន្លឹះនៃអសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា និងគួរតែប្រើប្រាស់ជាមូលដ្ឋានសម្រាប់រៀបចំយុទ្ធសាស្ត្រទៅអនាគត។

ការដោះស្រាយវិសមភាពនៃការទទួលបានអាហារ ទាមទារឱ្យបង្កើតផ្នែកគន្លឹះមួយ ក្នុងចក្ខុវិស័យនៃការមិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ និងរួមបញ្ចូលការកែលម្អ ការទទួលបាន ស្បៀងនៅតាមភូមិសាស្ត្រខុសៗគ្នា ក្រុមមនុស្សក្នុងសង្គម ជនជាតិភាគតិច និងក្នុងគ្រួសារ។ ប្រការនេះទាមទារនូវការវិភាគស៊ីជម្រៅដើម្បីធានាថា ការគាំទ្រត្រូវបានផ្តល់ឱ្យ នៅតំបន់ដែលមានឧបសគ្គចំពោះការទទួលបានស្បៀង ដែលទាក់ទងនឹងចំនួនប្រជាជន និង ប្រេវ៉ាឡង់ខ្ពស់នៃភាពក្រីក្រដោយកត្តាចម្រុះច្រើនយ៉ាង និងសូចនាករ

### ការយកចិត្តទុកដាក់អាចផ្តោតលើ៖

- កន្លែងដែលមានប្រេវ៉ាឡង់នៃភាពងាយរងគ្រោះខ្ពស់
- កន្លែងដែលបន្ទុកពិតមានកម្រិតខ្ពស់បំផុត (ពោលគឺ ប្រេវ៉ាឡង់អាចមិនខ្ពស់ប៉ុន្តែដោយសារដង់ស៊ីតេប្រជាជនខ្ពស់ ចំនួនដាច់ខាតនៃអ្នករងគ្រោះមានកម្រិតខ្ពស់ជាង) ឬ
- កន្លែងដែលការប្រឈមមានកម្រិតខ្ពស់ ដូចជា មានបញ្ហាប្រឈមចម្រុះត្រួតលើគ្នា។

អាហារូបត្ថម្ភមាន កម្រិតទាប។ ដើម្បីបង្កើនអំណាចទិញរបស់គ្រួសារក្រីក្រ និងដែលងាយរងគ្រោះជាងគេ និងរក្សាកំណើនដែលសម្រេចបានកន្លងមកក្នុងការកាត់បន្ថយភាពក្រីក្រ គេត្រូវការឱ្យមានការវិនិយោគយ៉ាងច្រើនសម្រាប់រយៈពេលវែង លើមូលធនមនុស្ស ក្រោមរូបភាពជាការកែលម្អលទ្ធភាពទទួលបានធនធាន ការអប់រំប្រកបដោយគុណភាព ការកែលម្អសុខភាព និងអាហារូបត្ថម្ភ។ ក្នុងរយៈពេលខ្លី ការយកចិត្តទុកដាក់គួរផ្តោតលើការពង្រឹករបរចិញ្ចឹមជីវិតសម្រាប់អ្នកជនបទ និងចក្ខុវិស័យក្នុងការសម្រេចបាន១០០% កំណើនផលិតភាព និងប្រាក់ចំណូលរបស់កសិករខ្នាតតូច (RGC, 2016) ការពង្រឹងសំណាញ់សុវត្ថិភាពសង្គម និងស្របជាមួយគ្នានេះ គឺការធ្វើឱ្យប្រសើរឡើងនៃជម្រើសដ៏ត្រឹមត្រូវក្នុងការទិញស្បៀង ដើម្បីធានាភាពចម្រុះនៃរបបអាហារដែលគ្រួសារអាចមានលទ្ធភាពទិញបាន ដោយរួមបញ្ចូលគ្រប់ក្រុមអាហារ រួមទាំង អាហារពីប្រភពសត្វផងដែរ។

កម្មវិធីគាំពារ និងសំណាញ់សុវត្ថិភាពសង្គម មានសារៈសំខាន់កាន់តែខ្លាំង និងត្រូវបានទទួលស្គាល់ថាជាមធ្យោបាយនៃការគាំទ្រការកែលម្អសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមថ្មីៗនេះ បានផ្តល់បរិបទគោលនយោបាយសម្រាប់កិច្ចការនេះ។ ការអនុវត្តក្របខ័ណ្ឌនេះក្នុងដំណាក់កាលដើមដំបូង តម្រូវឱ្យមានការគិតគូរចំពោះ (ក) បញ្ហាវិភាជន៍ធនធានសមស្រប និងការជួយដល់ជនងាយរងគ្រោះបំផុត (ខ) ការបញ្ជាក់បន្ថែមទៀតអំពីការចាត់ចែងអនុវត្ត ដើម្បីធានាឱ្យមានគណនេយ្យភាពសមស្រប (គ) ជំរុញការផ្សារភ្ជាប់ជាមួយការត្រៀមបង្ការ និងការឆ្លើយតបនឹងវិបត្តិ ដើម្បីអាចឱ្យគ្រួសារងាយរងគ្រោះទប់ទល់នឹងវិបត្តិនានាបានកាន់តែប្រសើរជាងមុន (ឃ) ការផ្តល់សេវាគាំពារសង្គមឱ្យជនក្រីក្រនៅតាមទីក្រុង ទាមទារឱ្យមានការគិតគូរឡើងវិញ។ ដូច្នេះ ការពង្រឹងកិច្ចគាំពារ និងសំណាញ់សុវត្ថិភាពសង្គម ទាមទារឱ្យមានប្រព័ន្ធវាស់វែង និងតាមដានត្រួតពិនិត្យឱ្យកាន់តែពេញលេញជាងមុន ដើម្បីស្វែងយល់ពីទិដ្ឋភាពជាច្រើននៃភាពងាយរងគ្រោះ និងគន្លឹះរបស់វា។ កត្តានេះអាចជួយដល់ការរៀបចំកម្មវិធី ឱ្យមានដំណើរស្របគ្នាជាមួយការពង្រឹងភាពឆ្លើយតបទៅនឹងវិបត្តិ ទាំងខាងប្រព័ន្ធគាំពារសង្គម និងយន្តការឆ្លើយតបមនុស្សធម៌ ដើម្បីការពារក្រុមជនងាយរងគ្រោះ។

### ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ( NSPPF )

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តឱ្យប្រើប្រាស់ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ដើម្បីលើកកម្ពស់នូវប្រព័ន្ធការពារសង្គមមួយដ៏រឹងមាំសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។ ពាក់ព័ន្ធនឹងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គោលនយោបាយនេះផ្តល់ជំនួយ ដែលរួមមានដូចជា ជំនួយបន្ទាន់ (ដូចជាការផ្គត់ផ្គង់ស្បៀងនៅពេលមានវិបត្តិ) ការគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ (ដូចជា ការលើកកម្ពស់អាហារូបត្ថម្ភ) និងកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់ម្ហូបអាហារដែលផលិតក្នុងស្រុក (RGC, 2017b)។

ការចំណាយទៅលើផ្នែកសង្គមកិច្ចសំខាន់ៗ នៅជុំវិញបញ្ហាសុខភាព និងការអប់រំ ជាបញ្ហាមួយសំខាន់បំផុតសម្រាប់គ្រួសារដែលងាយរងគ្រោះ។ កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសដែលមានអត្រាមរណមាតាខ្ពស់បំផុតនៅក្នុងតំបន់ (១៦១នាក់ក្នុងចំណោម ១០០.០០០កំណើតរស់ នៅឆ្នាំ២០១៥) (NIS, et al., 2001, 2015)។ ការសិក្សាមួយរបស់អង្គការ WFP (2017e) ក៏បានរកឃើញផងដែរថា ការចំណាយធំៗខាងផ្នែកសុខភាពបន្ទាប់ពីគ្រោះរាំងស្ងួតដោយសារបាតុភូតអែលនីញ៉ូអាចជាកត្តាដែលជំរុញឱ្យគ្រួសារនានាធ្លាក់ក្នុងបំណុល។

ក្នុងពេលដែល ការចំណាយរបស់រដ្ឋាភិបាលលើផ្នែកសុខាភិបាល និងការអប់រំ កំពុងកើនឡើង ដែលមានប្រមាណ ១,៣% សម្រាប់សុខាភិបាល និង ២,១% នៃ ផ.ស.ស សម្រាប់ការអប់រំ នៅឆ្នាំ ២០១៥ កម្ពុជានៅតែពឹងផ្អែកយ៉ាងខ្លាំងលើការផ្តល់មូលនិធិ ពីប្រភពក្រៅប្រទេស សម្រាប់ការផ្តល់សេវាកម្មនេះ។ ជំនួយសង្គមកិច្ចតាមសាលារៀន ក្នុងទម្រង់ជាស្បៀងអាហារ និងអាហារូបករណ៍ កំពុងទទួលបាន ការយកចិត្តទុកដាក់កាន់តែច្រើនឡើង ដើម្បីគាំទ្រដល់លទ្ធភាពចូលរៀនជាទៀងទាត់ សម្រាប់ពលរដ្ឋដែលងាយរងគ្រោះបំផុត ប៉ុន្តែនៅតែទាមទារឱ្យមានការពង្រីកបន្ថែមទៀត ដើម្បីឆ្លើយតបតាមតម្រូវការ។

**ភាពទទួលបានស្បៀង**

<u>ទាក់ទងនឹងភាពទទួលបានស្បៀង</u>
- កែលម្អរបរចិញ្ចឹមជីវិតរបស់ជនក្រីក្រ នៅជនបទ កសិករខ្នាតតូច

<u>ទាក់ទងនឹងការប្រើប្រាស់ស្បៀង</u>
- ពង្រីកការយល់ដឹងអំពីផលប៉ះពាល់ចំពោះអាហារូបត្ថម្ភ ដែល បណ្តាលមកពីលទ្ធភាពទទួលបានស្បៀងនៅមានកម្រិត
- ពង្រីកការយល់ដឹងពីអាទិភាពនិងភាពងាយស្រួលទទួលបានស្បៀង

<u>ទាក់ទងនឹងស្ថិរភាពស្បៀង</u>
- ពង្រីកផលិតកម្មស្បៀងនិងប្រព័ន្ធតាមដានថ្លៃ
- លើកកម្ពស់ភាពធន់
- ការឆ្លើយតបនឹងការប៉ះទង្គិចនៃប្រព័ន្ធគាំពារសង្គម និងពង្រីកយន្តការឆ្លើយតបផ្នែកមនុស្សធម៌

## ៥.៣ ការបឺតស្រូបស្បៀង៖ ការចាត់ទុកអាហារូបត្ថម្ភជាបញ្ហាអាទិភាព និងដោះស្រាយការប្រឈមដែលលេចឡើងថ្មី

**គោលដៅរង**

២.២ ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃបញ្ហាអាហារូបត្ថម្ភរួមទាំងការសម្រេចបាននៅឆ្នាំ២០២៥នូវ ចំណុចដៅដែលបានឯកភាពក្នុងកម្រិតអន្តរជាតិស្តីពីភាពក្រិសក្រិន និងភាពស្គមស្គាំងរបស់កុមារក្រោមអាយុ៥ឆ្នាំ និងដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន និងចាស់ជរា។

**ការពិចារណាជាយុទ្ធសាស្ត្រសម្រាប់កម្ពុជា**

» បង្កើនលទ្ធភាពទទួលបានទឹកស្អាត អនាម័យ សេវាសង្គម និងសុខភាព និងការផ្លាស់ប្តូរឥរិយាបថពាក់ព័ន្ធ
» កែលម្អការអនុវត្តការបំបៅកូន និងការផ្តល់អាហារដល់ទារក និងមាតា
» អាហារូបត្ថម្ភ និងវដ្តនៃជីវិត៖ អំឡុង1000ថ្ងៃដំបូង កុមារមុន ឬគ្រប់អាយុចូលរៀន កុមារជំទង់ ។ល។
» ដោះស្រាយបន្ទុកទ្វេដងនៃបញ្ហាអាហារូបត្ថម្ភ និងកំណើននៃជំងឺមិនឆ្លង
» ចាត់ទុកអាហារូបត្ថម្ភជាការវិនិយោគលើធនធានមនុស្ស៖ រៀបចំភស្តុតាងបង្ហាញ លើកកម្ពស់ការយល់ដឹង និងតស៊ូមតិជាមួយអ្នកធ្វើសេចក្តីសម្រេចចិត្តឱ្យគិតគូរអំពីចំនុចនេះ
» កែលម្អយុទ្ធសាស្ត្រ ក្នុងការរៀបចំសារសម្រាប់ផ្តល់ព័ត៌មាន និងការប្រាស្រ័យទាក់ទង។

នៅពេលថ្មីៗនេះផែនទីបង្ហាញផ្លូវដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភនៅកម្ពុជា ២០១៤-២០២០ ត្រូវបានបំពេញបន្ថែម ដោយផែនការសកម្មភាពជាតិស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា (២០១៦-២០២៥) បានប្រឹងប្រែងបង្កើនការសង្កត់ធ្ងន់លើការកែលម្អអាហារូបត្ថម្ភ ឆ្ពោះទៅសម្រេចចំណុចដៅ ២.២ នៃ SDG2 ៖ "**ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃបញ្ហា**

**អាហារូបត្ថម្ភ រួមទាំងការសម្រេចបាននៅឆ្នាំ២០២៥ នូវចំណុចដៅដែលបានឯកភាពនៅកម្រិតអន្តរជាតិស្តីពីភាពក្រិសក្រិន និងភាពស្គមស្គាំង របស់កុមារអាយុក្រោម៥ឆ្នាំ និងដោះស្រាយតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន និងចាស់ជរា”។** ដូច្នេះ នៅក្នុងលំដាប់លំដោយនៃការអនុវត្ត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDG) អាហារូបត្ថម្ភគួរតែត្រូវបានកំណត់ថាជា “កត្តាពន្លឿន” និងចាត់ទុកជាអាទិភាពខ្ពស់បំផុត ទើបអាចផ្តល់ផលជាវិជ្ជមានបន្ថែមទៀតក្នុងការសម្រេចបាន SDG ៣ (សុខភាព) ៤ (ការអប់រំ) ៥ (សមភាពយេនឌ័រ) ៨ (ការងារសមរម្យ) ៩ (ឧស្សាហកម្ម) និង ១០ (វិសមភាព)។ ដើម្បីឈានទៅមុខ ការចាត់ទុកករណីអាហារូបត្ថម្ភ ជាការវិនិយោគលើមូលធនមនុស្ស មានសារៈសំខាន់ជាខ្លាំងសម្រាប់ការផ្តល់ធនធានដើម្បីឆ្លើយតបនឹងចំណាត់អាទិភាពនេះ។ ប្រការនេះនឹងតម្រូវឱ្យមានការបង្កើនចំណេះដឹងជាបន្ថែមទៀតអំពីបញ្ហាអាហារូបត្ថម្ភក្នុងចំណោមអ្នកធ្វើការសម្រេចចិត្ត និងអ្នកផ្តល់ព័ត៌មាន។ ស្របគ្នានេះដែរ ចំណុចជាក់លាក់នានា និងការអនុវត្តកម្មវិធីជាតិអាហារូបត្ថម្ភក៏ត្រូវតែបានបញ្ជាក់ផងដែរ រួមទាំង ចំណងទាក់ទងច្បាស់លាស់ជាមួយការកែលម្អសន្តិសុខស្បៀង និងការទទួលបានទឹកស្អាត និងអនាម័យក៏ដូចជាការកំណត់ថ្លៃចំណាយ ការស្វែងរកមូលនិធិគាំទ្រ ទន្ទឹមនឹងការធានាឱ្យមានគណនេយ្យភាពច្បាស់លាស់។

> “នៅក្នុងលំដាប់លំដោយនៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា (CSDG) អាហារូបត្ថម្ភគួរតែត្រូវបានកំណត់ថាជា “កត្តាពន្លឿន” និងចាត់ទុកជាអាទិភាពខ្ពស់បំផុត ទើបអាចផ្តល់ផលជាវិជ្ជមានបន្ថែមទៀតក្នុងការសម្រេចបាន SDG ៣ (សុខភាព) ៤ (ការអប់រំ) ៥ (សមភាពយេនឌ័រ) ៨ (ការងារសមរម្យ) ៩ (ឧស្សាហកម្ម) និង ១០ (វិសមភាព)។”

យុទ្ធសាស្ត្រអន្តរាគមន៍ជាក់លាក់ផ្នែកអាហារូបត្ថម្ភ ដើម្បីដោះស្រាយបញ្ហាអាហារូបត្ថម្ភ ត្រូវពង្រឹងបន្ថែមលើការយល់ដឹងអំពីភាពស្មុគស្មាញ និងឫសគល់នៃបញ្ហាជាច្រើនដែលបង្កឱ្យមានបញ្ហាអាហារូបត្ថម្ភ។អត្រាបញ្ហាអាហារូបត្ថម្ភ មានលក្ខណៈខុសគ្នា ទៅតាមស្ថានភាពភូមិសាស្ត្រ និងដង់ស៊ីតេប្រជាជន និងរងការប៉ះពាល់ពីកត្តាសេដ្ឋកិច្ច និងសង្គម-វប្បធម៌ ស្ថានភាពអាហារូបត្ថម្ភរបស់មាតា និងវិបត្តិធម្មជាតិ និងសេដ្ឋកិច្ច (ដែលតែងតែកើតមានឡើងវិញជាញឹកញាប់) ។ នៅកម្រិតធំទូលាយជាងនេះ គេឃើញមានភាពចាំបាច់ដើម្បីបន្តការផ្តោតលើសុខភាពមាតា និងកិច្ចប្រឹងប្រែងគាំពារ ដូចជា ការធានាថា ស្ត្រីមានផ្ទៃពោះ និងម្តាយកំពុងបំបៅដោះកូន បានទទួលអាហារូបត្ថម្ភគ្រប់គ្រាន់ និងមានការអប់រំអំពីអាហារូបត្ថម្ភ ព្រមទាំងការប្រឹក្សាសម្រាប់ស្ត្រីមានផ្ទៃពោះ។ ជាមួយគ្នានេះដែរ កិច្ចប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាប្រេវ៉ាឡង់ខ្ពស់នៃភាពក្រិសក្រិន និងភាពស្គមស្គាំង គួរបន្តផ្តោតលើកុមារដែលបៅដោះតែមួយមុខ នៅក្នុងអំឡុងពេលប្រាំមួយខែដំបូងនៃកំណើតកូន ការធានាឱ្យមានការផ្តល់អាហារបំពេញបន្ថែមឱ្យបានគ្រប់គ្រាន់បន្ថែមលើការបំបៅដោះ សម្រាប់កុមារដែលមានអាយុ ៦ ដល់ ២៣ខែ (CARD et al., 2013; WFP, 2017d)។

ដូចដែលបានកត់សំគាល់ខាងលើ ការប្រឈមខាងសេដ្ឋកិច្ចនៃការទទួលបានស្បៀង អាចកាត់បន្ថយតាមរយៈការលើកកម្ពស់ពិពិធកម្មកសិកម្ម ក៏ដូចជា ការកែលម្អឱ្យមានការបញ្ចូលបន្ថែមមីក្រូសារជាតិនៅក្នុងអាហារ និងអាហារប្រចាំថ្ងៃក្នុងតម្លៃសមស្រប។ ចំណុចខាងក្រោយនេះទាមទារឱ្យមានកិច្ចប្រឹងប្រែងតាំងពីដើមដំបូង ដើម្បីពង្រឹង និងអនុវត្តច្បាប់នៅជុំវិញកម្មវិធីបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ (ដូចជា ការបន្ថែមជាតិអ៊ីយ៉ូដទៅក្នុងអំបិល ក្នុងចំណោមកម្មវិធីដទៃទៀត)។

ក្រៅពីនេះ ក៏មានភាពចាំបាច់ដើម្បីបង្កើនការទទួលបានសេវាសុខភាពជាមូលដ្ឋានផងដែរ (ការការពារ និងការព្យាបាល) ការអប់រំ ទឹកស្អាត និងអនាម័យ។ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ និងមនុស្សជំទង់ វាអាស្រ័យខ្លាំងទៅលើគុណភាពទឹក និងអនាម័យក្នុងនេះវឌ្ឍនភាពដែលសម្រេចបានភាគច្រើនគឺការទទួល

បានទឹកស្អាត ប៉ុន្តែតម្រូវឱ្យមានការកែលម្អលើការធ្វើតេស្តគុណភាពទឹក ដើម្បីធានាសុវត្ថិភាពឱ្យកាន់តែប្រសើរ។

ទម្លាប់ខាងសង្គម-វប្បធម៌ ក៏ត្រូវតែដោះស្រាយផងដែរ តាមរយៈអន្តរាគមន៍ជាក់លាក់លើផ្នែកអាហារូបត្ថម្ភ ដែលរាប់បញ្ចូល ការពង្រឹកសារ និងយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ដើម្បីកែប្រែអាកប្បកិរិយា (ដែលរួមទាំង ការត្រួតពិនិត្យលើការផ្សព្វផ្សាយពាណិជ្ជកម្ម ជាពិសេសនៅជុំវិញការបរិភោគអំបិល ស្ករ ខ្លាញ់ និងការធ្វើជាគំរូ ។ល។) អំពីអាហារូបត្ថម្ភ ដែលរួមទាំង កែលម្អទម្លាប់អនាម័យ និងការផ្តល់អាហារ។ ករណីនេះជាការពិត ចំពោះភាពក្រិសក្រិន ដែលកើតមានជាទូទៅ ទាំងក្នុងកន្លែងដែលស្បៀងមានតម្លៃទាប និងកន្លែងដែលស្បៀងមានតម្លៃខ្ពស់។ នេះជាការគូសបញ្ជាក់ពីសារៈសំខាន់នៃការប្រែអាកប្បកិរិយា ទើបអាចឈានដល់អត្រាកម្រិតសូន្យនៃករណីក្រិសក្រិន សម្រាប់កុមារដែលមានអាយុតិចជាងពីរឆ្នាំ នៅត្រឹមឆ្នាំ ២០៣០ (RGC, 2016)។

ការយកចិត្តទុកដាក់បច្ចុប្បន្នផ្តោតទៅលើរយៈពេល ១.០០០ថ្ងៃដំបូងនៃជីវិត។ ខណៈពេលមានតម្រូវការដើម្បីបន្តការវិនិយោគសម្រាប់បណ្តាលឆ្នាំដំបូងនៃជីវិត ដែលចាំបាច់ត្រូវពង្រីកការយកចិត្តទុកដាក់ចំពោះអាហារូបត្ថម្ភសម្រាប់វដ្តជីវិតទាំងមូល ដើម្បីធ្វើឱ្យការវិនិយោគនៅក្នុងរយៈពេល ១.០០០ថ្ងៃដំបូងនៃជីវិតទទួលបានផលល្អ។ កត្តានេះតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងដំណាលគ្នា ចំពោះក្រុមគោលដៅដទៃទៀត ដូចជាកុមារមុនអាយុចូលរៀន និងកុមារនៅអាយុចូលរៀននិងជាពិសេសក្មេងជំទង់ ដោយសារតែអត្រាខ្ពស់នៃការមានផ្ទៃពោះក្នុងចំណោមក្មេងជំទង់។

អត្រាប្រេវ៉ាឡង់នៃបញ្ហាអាហារូបត្ថម្ភនៅតែខ្ពស់ ទូទាំងផ្ទៃប្រទេស ជាពិសេស នៅតំបន់ខ្ពង់រាបភាគឦសាន។ ទោះជាយ៉ាងណាក៏ដោយ ដោយសារដង់ស៊ីតេខ្ពស់ នៃប្រជាជននៅតាមដងទន្លេសាប ចំនួនដាច់ខាតនៃប្រជាជនដែលខ្វះអាហារូបត្ថម្ភនៅតំបន់នេះច្រើនជាងនៅតំបន់ខ្ពង់រាបភាគឦសាន ដូចជា បញ្ហាដែលទាក់ទងនឹងភាពក្រិសក្រិន។ ដូច្នេះ គេត្រូវការឱ្យមានយុទ្ធសាស្ត្រអន្តរាគមន៍ដែលមានភាពវៃឆ្លាត ដើម្បីធានាថា មូលនិធិដែលមានក្នុងកម្រិតកំណត់ អាចដោះស្រាយតម្រូវការទាំងនៅក្នុងតំបន់ដែលមានចំនួនដាច់ខាតនៃប្រជាជនដែលខ្វះអាហារូបត្ថម្ភខ្ពស់បំផុត ក៏ដូចជា នៅក្នុងតំបន់ដែលមានប្រេវ៉ាឡង់ខ្ពស់បំផុតផងដែរ។

ស្របពេលជាមួយកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នដែលផ្តោតលើកម្រិតខ្ពស់នៃអត្រាភាពក្រិសក្រិន ការយកចិត្តទុកដាក់ហ្មត់ចត់ ត្រូវតែផ្តោតលើបញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវ (ស្គមស្គាំង) ក្នុងចំណោមកុមារអាយុក្រោមប្រាំឆ្នាំ ដែលមានការកែលម្អតិចតួចក្នុងរយៈពេលប្រាំឆ្នាំមកនេះ។ រាជរដ្ឋាភិបាលកម្ពុជាផ្តល់ការណែនាំអំពីការព្យាបាល ទាំងកង្វះអាហារូបត្ថម្ភកម្រិតមធ្យម និងកម្រិតស្រួចស្រាវធ្ងន់ធ្ងរ ទោះបីវិសាលភាពគ្របដណ្តប់នៃវិធានការព្យាបាល និងការទប់ស្កាត់ ទាមទារឱ្យមានការកែលម្អបន្ថែមក៏ដោយ។

ទីបញ្ចប់ ចំនុចបន្ថែមជាយុទ្ធសាស្ត្រ គឺតម្រូវឱ្យមានការដោះស្រាយបញ្ហានៃការកែប្រែរបបអាហារនៅជុំវិញការបរិភោគអាហារឆ្អិនស្រេច ការកើនឡើងនៃបញ្ហាលើសទម្ងន់ និងការកើនឡើងនៃជំងឺមិនឆ្លង។ បញ្ហានេះទាក់ទងនឹងនគរូបនីយកម្មយ៉ាងឆាប់រហ័ស ការបរិភោគបាយច្រើនពេកនៅក្នុងរបបអាហារ និងការបរិភោគអាហារសម្រន់កាន់តែច្រើន ជាពិសេស ក្នុងចំណោមកុមារ។ បញ្ហានេះជាប់ពាក់ព័ន្ធជាពិសេសជាមួយស្ត្រីក្នុងវ័យបន្តពូជនៅតាមទីក្រុង ប៉ុន្តែក៏កើនឡើងផងដែរនៅតាមទីជនបទ និងកើតលើមនុស្សគ្រប់ក្រុមក្នុងសង្គម។ ស្ត្រីនៅទីក្រុងចំនួន២២,៥% លើសទម្ងន់ ឬមានរោគធាត់ ធៀបនឹង១៧% នៅតាមទីជនបទ និង២៥% ក្នុងចំណោមកុមារអាយុក្រោម ៥ឆ្នាំ (NMCHC, 2016; NIS et al., 2015; WFP, 2017d)។

ផ្អែកតាមសូចនាករអាហារូបត្ថម្ភ តាមរយៈការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា ក្រុមគោលដៅសំខាន់ៗដែលបានកំណត់មានជាអាទិ៍ កុមារ និងស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះ

កូននៅអំឡុង ១.000ថ្ងៃដំបូង កុមារមុនអាយុចូលរៀន និងកុមារនៅអាយុចូលរៀន និងកុមារីជំទង់។ ទោះជាយ៉ាងណាក៏ដោយ ការទទួលស្គាល់ពីតួនាទីគន្លឹះរបស់បុរស នៅក្នុងគ្រួសាររបស់ខ្លួន និងតួនាទីកាន់តែច្រើនឡើងនៃមនុស្សចាស់ ក្នុងការថែទាំកុមារក្នុងករណីឪពុកម្តាយធ្វើចំណាកស្រុក បញ្ហាទាំងនេះ ក៏ត្រូវតែជាគោលដៅមួយដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងបង្កើនការយល់ដឹងផងដែរ។

**ការបើតស្រូបស្បៀង**

<u>ទាក់ទងនឹងភាពមានស្បៀង</u>
- កសិកម្មដែលគិតគូរពីអាហារូបត្ថម្ភ
- អាហារបន្ថែមសារធាតុចិញ្ចឹម ដែលរួមទាំងការបញ្ចូលសារជាតិទៅក្នុងចំណីអាហារ (ដូចជា ការបន្ថែមអ៊ីយ៉ូដទៅក្នុងអំបិល ក្នុងចំណោមអន្តរាគមន៍ផ្សេងទៀត)

<u>ទាក់ទងភាពទទួលបានស្បៀង</u>
- ពង្រីកការយល់ដឹងអំពីរបបអាហាដែលមានតម្លៃសមស្រប

<u>ទាក់ទងនឹងស្ថិរភាពស្បៀង</u>
- ការបន្តទទួលបានសេវា ការកាត់បន្ថយឲ្យនៅកម្រិតអប្បបរមានូវការរំខានចំពោះសេវាដោយសារវិបត្តិ (ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត។ល។)

## ៥.៤ ស្ថិរភាពស្បៀង៖ ត្រូវបន្តធានាភាពមានស្បៀង ភាពទទួលបានស្បៀង និងការបើតស្រូបស្បៀងក្នុងករណីមានវិបត្តិ តាមរយៈការកាត់បន្ថយហានិភ័យ និងវិធានការគាំពារសង្គម

2 ZERO HUNGER

### គោលដៅរង

២.៤ ត្រឹមឆ្នាំ២០៣០ ធានានូវប្រព័ន្ធផលិតកម្មស្បៀងដែលមានចីរភាព អនុវត្តកសិកម្មដែលធន់ទ្រាំនឹងបម្រែបម្រួលអាសធាតុ ដែលអាចបង្កើនផលិតភាព និងផលិតកម្ម ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ី និងពង្រឹងសម័ត្ថភាពបន្សាំនឹងបម្រែបម្រួលអាកាសធាតុ គ្រោះរាំងស្ងួត ទឹកជំនន់ និងគ្រោះមហន្តរាយដទៃទៀត និងកែប្រែគុណភាពដីជាបន្តបន្ទាប់។

### ការពិចារណាជាយុទ្ធសាស្ត្រសម្រាប់កម្ពុជា

- » កែលម្អប្រព័ន្ធគាំពារសង្គម ដោយគិតគូរបន្ថែមចំពោះសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីឆ្លើយតបឱ្យបានប្រសើរទៅនឹងវិបត្តិ
- » បង្កើនការបន្សាំ នឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រួមបញ្ចូលទាំងការពារទប់ទល់នឹងការរិចរិលបរិស្ថាន
- » បន្តដើម្បីពង្រឹងលើយន្តការគ្រប់គ្រងគ្រោះមហន្តរាយ (កាត់បន្ថយហានិភ័យ ការត្រៀមខ្លួន និងអន្តរាគមន៍) ចំពោះរាល់វិបត្តិដែលអាចកើតមាន (ដូចជា វិបត្តិអាកាសធាតុ សេដ្ឋកិច្ច សុខភាព ជាដើម)
- » បង្កើនភាពធន់របស់សហគមន៍ចំពោះវិបត្តិនានា

ក្នុងស្ថានភាពដែលកម្ពុជាងាយរងគ្រោះដោយសារហានិភ័យពី កត្តាធម្មជាតិ និង សេដ្ឋកិច្ច កិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្ន ត្រូវតែផ្តោតលើការកែលម្អការអនុវត្ត និងការឆ្លើយតបនៃយន្តការគាំពារសង្គមទៅនឹងហានិភ័យទាំងនោះ ក្នុងន័យការពារការសម្រេចបានសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទន្ទឹមនឹងពង្រីកភាពធន់នៃសហគមន៍ទៅនឹងអាកាសធាតុ និងហានិភ័យដោយសារកត្តាមនុស្ស។ កម្រិតនៃការយល់ដឹងទាបនាពេលបច្ចុប្បន្ន និងវិសាលភាពនៃជំនួយសង្គមកិច្ច ព្រមទាំងយន្តការធានារ៉ាប់រងសង្គមនៅមាន

កម្រិតទាប[2] តម្រូវឱ្យមានការពង្រីកបន្ថែមនូវធនធានរបស់ពួកគេ និងការរៀបចំការអនុវត្ត។ ការកើនឡើងនៃនិន្នាការចំណាកស្រុក បានដើរតួជាយន្តការទប់ទល់សម្រាប់មនុស្សជាច្រើន និងបានរួមចំណែកផ្តល់ធនធានដ៏មានតម្លៃ ដល់គ្រួសារនានា តាមរយៈប្រាក់ដែលផ្ញើមកផ្ទះ ហើយទាមទារឱ្យមានការវិភាគបន្ថែមអំពីផលប៉ះពាល់នៃចំណាកស្រុកមកលើកិច្ចគាំពារសង្គម។ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥) មានគោលដៅរៀបចំផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដើម្បីធានាសុវត្ថិភាពប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋចំពោះផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សផ្នែកនគរូបនីយកម្ម និង ហេដ្ឋាចនាសម្ព័ន្ធ ការរៀបចំឱ្យមានផែនការអភិវឌ្ឍន៍ទីក្រុងឱ្យបានសមស្រប និងការពង្រឹងភាពធន់នៃហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជា មានសារៈសំខាន់ណាស់ ដែលរួមទាំង ការសាងសង់ផ្លូវថ្នល់ដែលធន់នឹងទឹកជំនន់ ការគោរពតាមស្តង់ដារអប្បបរមានៃសំណង់ ការធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍន៍ទីក្រុង និងការបង្កើនមូលដ្ឋានគ្រឹះសម្រាប់អណ្តូងទឹក និងសម្បទាអនាម័យ ដើម្បីទប់ស្កាត់ការជន់លិចនៅរដូវវស្សា។ ទន្ទឹមនឹងនេះ ការថែរក្សាធនធានធម្មជាតិទាមទារឱ្យមានការពង្រឹងជាបន្ថែម តាមរយៈការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងព្រៃឈើឱ្យមាននិរន្តរភាពដែលបង្កើតជាផ្នែកស្នូលមួយនៃភាពធន់នឹងអាកាសធាតុ។

ក្របខ័ណ្ឌសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានកំណត់ក្នុងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយឆ្នាំ ២០១៥។ ទោះជាយ៉ាងណាក៏ដោយ ភាពច្បាស់លាស់សម្រាប់ការអនុវត្តច្បាប់នេះ ទាមទារឱ្យមានការរៀបចំអនុក្រឹតពាក់ព័ន្ធដើម្បីបង្ហាញពីគណនេយ្យភាព និងការធានាឱ្យមានថវិកាសម្រាប់ការអនុវត្ត។ ចំណុចចុងក្រោយនេះ ទាមទារឱ្យមានការផ្តោតបន្ថែមទៀតលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលរួមទាំងកិច្ចការពារភាពរេចរឹលបរិស្ថានផងដែរ ក៏ដូចជាការពង្រឹងយន្តការសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ (កាត់បន្ថយហានិភ័យ ការត្រៀមបង្ការ និងការឆ្លើយតប) ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់គ្រប់វិបត្តិដែលអាចកើតមាន (វិបត្តិបណ្តាលពីអាកាសធាតុ សេដ្ឋកិច្ច សុខភាព។ល។)។

ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយហានិភ័យ ការត្រៀមបង្ការ និងការឆ្លើយតប ការប្រមូលព័ត៌មាន ការវិភាគ និងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធ អំពីភាពងាយរងគ្រោះនៃប្រជាជននៅតាមតំបន់ភូមិសាស្ត្រខុសៗគ្នា ការតាមដានធាតុអាកាស ការប្រកាសផ្តល់ព័ត៌មានជាមុន និងការតាមដាននិន្នាការតម្លៃទំនិញ គឺជាតម្រូវការចាំបាច់ ដើម្បីបង្កើនការយល់ដឹងអំពីវិបត្តិនានាដែលអាចកើតមាន និងជាមគ្គុទេសក៍សម្រាប់អ្នករៀបចំគោលនយោបាយ។

2 *កម្មវិធីជំនួយសង្គមកិច្ច មានជាអាទិ៍ ១. ការបម្រុងទុកស្បៀង ២. កម្មវិធីអាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារ ៣. អាហារូបករណ៍សម្រាប់កម្រិតបឋមសិក្សា ៤. កម្មវិធីផ្តល់អាហារតាមសាលារៀន និង ៥. ការបណ្តុះបណ្តាលវិជ្ជាជីវៈ។ កម្មវិធីធានារ៉ាប់រងសង្គម រួមបញ្ចូល បេឡាជាតិរបបសន្តិសុខសង្គម (NSSF) ក៏ដូចជា មូលនិធិដោយឡែកសម្រាប់មន្ត្រីរាជការចូលនិវត្តន៍ និងជនពិការ និងមូលនិធិសមធម៌សុខភាព (HEF) ដើម្បីការពារទល់នឹងអសន្តិសុខប្រាក់ចំណូល។*

## ៦. ការរៀបចំអភិបាលកិច្ចសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

បញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅតែជាកង្វល់គន្លឹះនៅកម្ពុជា និងមានសារៈសំខាន់ចំពោះការអភិវឌ្ឍមូលធនមនុស្ស។ ដើម្បីសម្រួលឱ្យមានការសម្របសម្រួលបញ្ហាអន្តរវិស័យទាំងនេះ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទត្រូវបានបង្កើតឡើង ដើម្បីធ្វើការតាមដានត្រួតពិនិត្យ និងដឹកនាំអនុវត្តការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានតួនាទីជាក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រ ហើយទិសដៅទៅមុខ ទាមទារឱ្យមានការតម្រង់ទិសច្បាស់លាស់ឱ្យស៊ីសង្វាក់គ្នាជាមួយក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងទៀត ដូចជា យុទ្ធសាស្ត្ររបស់ក្រសួងនានា ផែនការសកម្មភាពជាតិស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅកម្ពុជា(២០១៦-២០២៥) និងផែនទីបង្ហាញផ្លូវដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភនៅកម្ពុជា ២០១៨-២០២០។ ការផ្តោតកាន់តែច្រើនលើអាហារូបត្ថម្ភ គឺជាការអភិវឌ្ឍនៅក្នុងពេលថ្មីៗនេះ ខាងផ្នែកគោលនយោបាយ ដោយសង្កត់ធ្ងន់លើតម្រូវការក្នុងពេលបច្ចុប្បន្ន ដើម្បីផ្តល់អាទិភាពដល់អាហារូបត្ថម្ភ នៅក្នុងកិច្ចខិតខំប្រឹងប្រែងអនុវត្តនានា។ ក្នុងពេលជាមួយគ្នានេះដែរ ប្រការចាំបាច់គឺ ត្រូវធានាឱ្យមានការយល់ដឹងអំពីចំណងទាក់ទងនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ និន្នាការធំទូលាយដែលទាក់ទងនឹងជីវភាពរស់នៅ មុខរបរ ចំណាកស្រុក និងនគរូបនីយកម្ម ក៏ត្រូវតែលើកយកមកពិចារណាផងដែរ ដើម្បីស្វែងយល់ឱ្យបានពេញលេញនូវបរិបទគោលនយោបាយ និងការធានាឱ្យមានវិធានការឆ្លើយតបស៊ីសង្វាក់គ្នា។

បច្ចុប្បន្ន យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានសកម្មភាពអាទិភាពច្រើនជាង ៦០ និងសូចនាករពាក់ព័ន្ធច្រើនជាង១០០។ ដើម្បីបន្ថែមភាពច្បាស់លាស់ជាអាទិភាព សកម្មភាព និងសូចនាករទាំងនេះ គួរតែបានកាត់បន្ថយមកត្រឹមអាទិភាពស្នូលអន្តរវិស័យមួយចំនួនតូច ដែលមានលំដាប់លំដោយជាបន្តបន្ទាប់ទៅតាមពេលវេលា និងជាមួយបង្គុំសូចនាករពាក់ព័ន្ធដែលមានចំនួនតិចជាងនេះ។ កត្តានេះអាចជួយឱ្យមានការផ្សារភ្ជាប់ជាមួយយុទ្ធសាស្ត្រនានារបស់ក្រសួងពាក់ព័ន្ធ និងការតាមដានត្រួតពិនិត្យសកម្មភាពលម្អិត តាមវិស័យឱ្យបានកាន់តែច្រើន។ ដើម្បីធ្វើឱ្យគោលនយោបាយអាចសម្រេចបាន ការរៀបចំអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដែលមានលក្ខណៈអន្តរវិស័យ និងយុទ្ធសាស្ត្រពាក់ព័ន្ធ ទាមទារនូវការពង្រឹងបន្ថែមទៀត ដោយធានាថារាជរដ្ឋាភិបាលកម្ពុជាត្រូវតែដឹកនាំការងារនេះ ដោយឯកភាពលើវិស័យនានាដែលផ្តល់តម្លៃបន្ថែម សម្រាប់ការងារចម្រុះ និងផ្នែកនានាដែលក្រសួងពាក់ព័ន្ធនីមួយៗអាចជំរុញទៅមុខ។ កិច្ចការនេះតម្រូវឱ្យមានការចែងច្បាស់លាស់អំពីគណនេយ្យភាពរបស់ក្រសួងពាក់ព័ន្ធនានា ហើយជនបង្គោលគួរតែបានទទួលអំណាច ដើម្បីចាត់វិធានការទៅតាមនេះផងដែរ។ អាទិភាពអន្តរវិស័យដែលទាក់ទងនឹងក្រសួងនានាអាចរួមមាន៖ (១) ពង្រឹងការផ្តោតលើទស្សនវិស័យនៃការមិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ (២) លើកកម្ពស់ "ការចូលរួមនៃសង្គមទាំងមូល" (៣) ពង្រឹងហិរញ្ញប្បទានពីប្រភពក្នុងស្រុក ពីវិស័យសាធារណៈ និងឯកជន សម្រាប់វិស័យអាទិភាពដែលបានកំណត់ខាងលើ (៤) ពង្រឹងការគ្រប់គ្រងព័ត៌មាននិងចំណេះដឹងអំពីវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីធានាការធ្វើសេចក្តីសម្រេចដែលផ្អែកលើព័ត៌មានគ្រប់គ្រាន់និងភស្តុតាងជាក់លាក់ និង (៥) កៀងគរការគាំទ្រពហុជំនាញសម្រាប់កិច្ចផ្តួចផ្តើមអន្តរវិស័យមួយចំនួន ដូចជា ការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ និងការកែលម្អគុណភាពទឹក និងអនាម័យ។

ការគាំទ្ររឹងមាំ ត្រូវបានអនុវត្តរួចមកហើយ សម្រាប់អភិក្រមចម្រុះ ដែលអាចអនុញ្ញាតឱ្យមានវឌ្ឍនភាពលើគ្រប់ផ្នែកសំខាន់ៗនៃការអនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។ ដើម្បីពង្រឹងបន្ថែមលើអ្វីដែលមានរួចមកហើយ ត្រូវមានការកំណត់តម្លៃចំណាយសម្រាប់សកម្មភាពអាទិភាព ហើយធន

ធានសម្រាប់ការអនុវត្តត្រូវគិត ទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ ជាមួយដំណើរការរៀបចំផែនការ និងការស្វែងរកធនធានក្នុងស្រុកដោយមានការបន្សុីគ្នា ដើម្បីធានាសម្រេចបានកិច្ចការនេះ។ អភិក្រមហិរញ្ញប្បទានក្នុងស្រុកតាមបែបច្នៃប្រឌិត ត្រូវតែបានពង្រឹង និងបំពេញដោយជំនួយពីក្រៅប្រទេសដែលនៅសេសសល់ ដែលនៅតែបន្តទទួលស្គាល់បញ្ហាអាហារូបត្ថម្ភ និងកិច្ចគាំពារសង្គមនៅកម្ពុជា។ កម្ពុជាមានកាលានុវត្តិភាពឆ្ពោះទៅបង្កើតដំណោះស្រាយហិរញ្ញប្បទានបែបច្នៃប្រឌិតនៅក្នុងប្រទេសតាមរយៈវិភាជន៍ថវិកាពីរដ្ឋាភិបាលឱ្យបានរឹងមាំ ភាពជាដៃគូបែបច្នៃប្រឌិតរវាងវិស័យសាធារណៈ-ឯកជន និងការលើកទឹកចិត្តឱ្យមានការវិនិយោគត្រឹមត្រូវចំពោះប្រាក់ដែលផ្ញើមកផ្ទះ ដើម្បីលើកកម្ពស់សន្តិសុខស្បៀងតាមគ្រួសារឱ្យកាន់តែទូលាយជាងមុន។ ដើម្បីធានាឱ្យមានការផ្តល់ធនធានសមស្រប យុទ្ធសាស្ត្រនានាត្រូវតែបានកំណត់តម្លៃចំណាយសមស្រប។ បច្ចុប្បន្ន ការធ្វើបែបនេះត្រូវបានអនុវត្តសម្រាប់ផ្នែកមួយចំនួនប៉ុណ្ណោះ។ ឧទាហរណ៍ ផែនទីបង្ហាញផ្លូវដើម្បីពន្លឿនការកែលម្អអាហារូបត្ថម្ភនៅកម្ពុជា ២ ០១៤-២០២០ នៅ ពេលថ្មីៗនេះបានគណនាតម្លៃចំណាយសម្រាប់សកម្មភាពនានាក្នុងកម្រិត ៥០លានដុល្លា ក្នុងនោះមានថវិការដ្ឋតែប្រមាណ ៣០% ដែលរកបាន សម្រាប់បំពេញការចំណាយនេះ។ ដូចគ្នានេះដែរ ថវិកាកម្មវិធីវិនិយោគសាធារណៈ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ឆ្នាំ ២០១៨-២០២០ ដែលមានទឹកប្រាក់ ២៧៥លានដុល្លា មានត្រឹមតែប្រមាណ ៤២,៤លានដុល្លាប៉ុណ្ណោះ ដែលនឹងទទួលបាន សម្រាប់កិច្ចការនេះ ចំណែកការផ្តល់មូលនិធិពីក្រៅប្រទេស តាមរយៈកំចីអនុគ្រោះពីស្ថាប័នហិរញ្ញវត្ថុ ដូចជា IFAD និង ADB មានច្រើនជាង ៥០% នៃទឹកប្រាក់សរុបដែលត្រូវការ។ ចំពោះយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភផ្ទាល់ គឺពុំមានថវិកាឡើយ ហើយធនធានដែលផ្តល់ឱ្យប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដើម្បីសម្របសម្រួលកិច្ចការនេះគឺមានកម្រិតតិចតួច (WFP, 2017c)។

ការអនុវត្តឱ្យមានប្រសិទ្ធភាព ក៏ទាមទារឱ្យពង្រឹងការរៀបចំចាត់ចែងអនុវត្តនៅថ្នាក់ក្រោមជាតិផងដែរ។ ការផ្តោតបច្ចុប្បន្ននៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ គឺនៅថ្នាក់ជាតិ ដោយគ្មានការរៀបចំចាត់ចែងនៅថ្នាក់ក្រោមជាតិឡើយ។ កិច្ចប្រឹងប្រែងវិមជ្ឈការដែលកំពុងអនុវត្ត អាចធ្វើឱ្យរចនាសម្ព័ន្ធអភិបាលកិច្ចថ្នាក់ខេត្តពង្រឹងបន្ថែម ដើម្បីធានាថា រចនាសម្ព័ន្ធទាំងនេះផ្តោតការយកចិត្តទុកដាក់លើបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការសម្របសម្រួលជាមួយមន្ទីរពាក់ព័ន្ធនៅថ្នាក់ខេត្ត និងស្ថាប័នដទៃទៀត។ គន្លឹះចំពោះកិច្ចការនេះ គឺត្រូវធានាឱ្យមានការចូលរួមពីសង្គមស៊ីវិល និងវិស័យឯកជនដើម្បីពង្រឹងសេវាសាធារណៈ តាមរយៈអភិក្រមដែលផ្តោតលើសហគមន៍ ដែលរួមទាំងការពឹងផ្អែកលើរចនាសម្ព័ន្ធស្ម័គ្រចិត្តដែលមានស្រាប់ ។

កម្ពុជាបានបោះជំហានយ៉ាងសំខាន់ដោយបានចូលរួមជាមួយចលនាបង្កើនកិច្ចអន្តរាគមន៍អាហារូបត្ថម្ភពិភពលោកនៅក្នុងខែ កក្កដា ឆ្នាំ ២០១៤ ជាមួយកិច្ចខិតខំប្រឹងប្រែងកំពុងតែអនុវត្ត ដើម្បីបង្កើតយុទ្ធសាស្ត្រច្បាស់លាស់ និងកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចចំណុចដៅទាំងនេះ។ ដើម្បីឈានទៅមុខ **"អភិក្រមសង្គមទាំងមូល"** នឹងសម្រួលឱ្យមានការចូលរួមនៃអ្នកពាក់ព័ន្ធទាំងអស់។ ជនបង្គោលដែលបានតែងតាំងជាផ្លូវការ ត្រូវតែដឹកនាំ ឬចូលរួមនៅក្នុងដំណើរការនេះនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ អ្នករៀបចំគោលនយោបាយ និងអ្នកគ្រប់គ្រង ត្រូវតែចូលរួមក្នុងដំណើរការនេះ ទទួលបានការសាងសមត្ថភាព និងពង្រឹងសិទ្ធិអំណាចទៅតាមសមត្ថកិច្ចសមស្របរបស់ខ្លួន ឧទាហរណ៍ដូចជា សមាជិកសភា អភិបាលខេត្ត ក្រុមប្រឹក្សាឃុំជាដើម។ ការចូលរួមជាមួយវិស័យឯកជន គឺជាការចាំបាច់ ដើម្បីបង្កើនការយល់ដឹង និងពង្រីកធនធានដែលមានសក្តានុពល (បច្ចេកទេស សម្ភារៈ ហិរញ្ញវត្ថុ សមត្ថភាព) និងភាពជាដៃគូ ឧទាហរណ៍ ដូចជា ដើម្បីពង្រីកការយល់ដឹងនៅក្នុងឧស្សាហកម្មកាត់ដេរ ឬពង្រីកមធ្យោបាយ ដើម្បីពង្រឹងការអនុវត្តច្បាប់ និង គោលនយោបាយស្តីពីការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ (WFP, 2017f)។ កិច្ចការនេះត្រូវតែស្របគ្នាជាមួយកិច្ចប្រឹងប្រែងដើម្បីប្រើប្រាស់ប្រព័ន្ធ

ផ្សព្វផ្សាយសាធារណៈ ដើម្បីលើកទឹកចិត្តឱ្យមានការរាយការណ៍ ព័ត៌មាន និងគ្រឹះស្ថានឧត្តមសិក្សា ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងស្រាវជ្រាវ។

ដើម្បីអាចឱ្យមានអភិក្រមសម្របសម្រួលអន្តរវិស័យនៅច្រើនលំដាប់ថ្នាក់ ការប្រមូលព័ត៌មាន ការវិភាគ និងការផ្សព្វផ្សាយ ត្រូវតែបានពង្រឹងនិងដាក់ឱ្យដំណើរការ តាមរយៈវេទិការួមមួយ ដោយពង្រឹងជាបន្ថែមលើការពង្រីកលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យានៅទូទាំងប្រទេសកម្ពុជា និងការធានាឱ្យមានការកសាងសមត្ថភាពបុគ្គលិកនៅគ្រប់លំដាប់ថ្នាក់។ ដើម្បីសម្រេចបានលទ្ធផលក្នុងវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភប្រសើរជាងមុន និងដែលមាននិរន្តរភាព គឺទាមទារឱ្យមានការពង្រីកសកម្មភាព បង្កើនការយល់ដឹង ដែលរួមទាំងតាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈ សាលារៀន និងយន្តការសហគមន៍។

## ក្របខណ្ឌសន្តិសុខស្បៀង និងអាហារូបត្ថម្ភថ្មី

កិច្ចប្រឹងប្រែងជាសាកលមួយកំពុងត្រូវបានធ្វើឡើងដើម្បីធ្វើយ៉ាងណាឱ្យក្របខ័ណ្ឌស្តីពីសន្តិសុខស្បៀង អាចឆ្លុះបញ្ចាំងអំពីនិន្នាការដែលលេចឡើងថ្មី ក៏ដូចជាភាពស្មុគស្មាញ និងទំនាក់ទំនងរវាងកត្តាជាច្រើន។ ក្របខ័ណ្ឌថ្មីមួយដែលមានចែងនៅក្នុងរបាយការណ៍ថ្មីៗនេះ ស្តីពីប្រព័ន្ធស្បៀង និងអាហារូបត្ថម្ភ រៀបចំដោយក្រុមអ្នកជំនាញការជាន់ខ្ពស់ខាងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ អាចផ្តល់អភិក្រមគ្រប់ជ្រុងជ្រោយជាងនេះដើម្បីឆ្លុះបញ្ចាំងបរិបទនៃការវិវត្តនៅកម្ពុជា (HLPE, 2017)។ ក្របខ័ណ្ឌនេះផ្តល់ជាទ្រឹស្តីអំពីការប្រែប្រួលដែលសមស្របទៅនឹងការរៀបចំផែនការយុទ្ធសាស្ត្រទៅអនាគត និងឯកសារខ្លះៗដែលបច្ចុប្បន្នកំពុងស្ថិតក្នុងការរៀបចំនៅក្នុងយុទ្ធសាស្ត្រ ដែលមានស្រាប់។ មូលដ្ឋានគ្រឹះនៃសន្តិសុខស្បៀង នឹងការបន្ស៊ីជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព មានឆ្លុះបញ្ចាំងនៅក្នុងក្របខ័ណ្ឌនេះ។

# ៧. អនុសាសន៍ និងសេចក្តីសន្និដ្ឋាន

ជាមួយការគាំទ្ររឹងមាំដើម្បីឱ្យមានអភិក្រមពេញលេញមួយ ដើម្បីប្រយុទ្ធប្រឆាំងអសន្តិសុខស្បៀង និងបញ្ហាអាហារូបត្ថម្ភ និងវឌ្ឍនភាពយ៉ាងធំដែលសម្រេចបាននៅលើគ្រប់វិស័យនៅក្នុងការអនុវត្តផែនការសកម្មភាពជាអាទិភាពរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨ លំនាំវិជ្ជមាននេះត្រូវតែរក្សាឱ្យឈានទៅមុខរហូត។ នៅត្រង់ចំណុចប្រសព្វដ៏សំខាន់នេះ ការវិនិយោគលើការប្រយុទ្ធប្រឆាំងបញ្ហាអាហារូបត្ថម្ភ នឹងផ្តល់ជាការបង្កើនល្បឿនវឌ្ឍនភាពនៅលើវិស័យផ្សេងទៀត និងជួយរក្សានិរន្តរភាពនៃកំណើនសេដ្ឋកិច្ច។ គោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ដែលទាក់ទងនឹង សន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានដាក់ឱ្យប្រើប្រាស់រួចមកហើយ ទន្ទឹមនឹងការប្តេជ្ញាកម្រិតខ្ពស់ក្នុងការចាត់ទុកអាហារូបត្ថម្ភជា អាទិភាពបំផុតនៃកិច្ចខិតខំប្រឹងប្រែងនានា។ ការពិនិត្យពាក់កណ្តាលអាណត្តិនេះ បញ្ជាក់អះអាងថា យុទ្ធសាស្ត្របច្ចុប្បន្នមានលក្ខណៈសមស្រប និងគួរតែនៅបន្តផ្តល់ការណែនាំដល់ កិច្ចខិតខំប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធ នៅក្នុងការដោះស្រាយចំណុចដៅ ដែលបានកំណត់សម្រាប់ឆ្នាំ ២០១៨។ ដំណើរការពិនិត្យពាក់កណ្តាលអាណត្តិនេះ មានតួនាទីផ្តល់ជាការពង្រឹងការយល់ដឹង និងការផ្តោតឡើងវិញលើកិច្ចប្រឹងប្រែងរបស់យើងនៅជុំវិញសកម្មភាព និងការទទួលខុសត្រូវស្នូល។ កម្លាំងថាមពលនេះត្រូវតែរក្សាទៅមុខ និងបង្កើនកិច្ចប្រឹងប្រែង ដើម្បីឈានដល់ចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំ ២០១៨។ មានការប្រមើលឃើញថាកត្តាប្រឈមដូចគ្នានេះដែលជួបប្រទះក្នុងដំណើរការ ពិនិត្យពាក់កណ្តាលអាណត្តិពាក់ព័ន្ធនឹងការប្រមូលទិន្នន័យ និង ការវាយតម្លៃអំពីវឌ្ឍនភាព ក៏នឹងកើតមានឡើងទៀត នៅក្នុងការសន្និដ្ឋាននៅដំណាក់កាលចុងក្រោយនៃការអនុវត្តយុទ្ធសាស្ត្រនេះដោយសារការពឹងផ្អែកជាខ្លាំងលើការអង្កេតសុខភាពនិងប្រជាសាស្ត្ររបស់ប្រទេសកម្ពុជា (CDHS) ដើម្បីវាស់វែងទិដ្ឋភាពជាច្រើននៃវឌ្ឍនភាព។

"ការពិនិត្យពាក់កណ្តាលអាណត្តិនេះ បញ្ជាក់អះអាងថា យុទ្ធសាស្ត្របច្ចុប្បន្នមានលក្ខណៈសមស្រប និងគួរតែនៅបន្តផ្តល់ការណែនាំដល់កិច្ចខិតខំប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធនៅក្នុងការដោះស្រាយចំណុចដៅដែលបានកំណត់សម្រាប់ឆ្នាំ២០១៨។"

ដើម្បីពង្រឹងជាបន្ថែមដោយផ្អែកលើកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លានេះនិងដើម្បីត្រៀមខ្លួនសម្រាប់រៀបចំយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភខាងមុខ នៅក្នុងរយៈពេលខ្លី រហូតដល់ឆ្នាំ២០១៨ ការយកចិត្តទុកដាក់គួរតែផ្តោតលើ៖

- **ការកែលម្អផែនទីបង្ហាញផ្លូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ឆ្នាំ២០៣០ ដោយផ្អែកលើ SDGs របស់កម្ពុជាដែលបានអនុម័ត** និងសកម្មភាពនានាដែលមានស្រាប់ ព្រមទាំងសូចនាករនានានៅក្នុង សូចនាករពិនិត្យតាមដានរួមគ្នា(JMIs) និងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀ ង និងអាហារូបត្ថម្ភដើម្បីធ្វើសនិទានកម្មសូចនាករ ចំណុចដៅ និងប្រព័ន្ធព័ត៌មាន។
- **ត្រូវកំណត់ប្រភពហិរញ្ញវត្ថុ** ដែលអាចទាញយកមកប្រើប្រាស់ទៅអនាគត ដើម្បីជួយនៅក្នុងការអនុវត្តនៅផ្នែកដែលពុំទទួលបាន មូលនិធិគ្រប់គ្រាន់។ ប្រការនេះនឹងទាមទារឱ្យមានការប្រាស្រ័យទាក់ទងដ៏រឹងមាំជាបន្ត អំពីសារៈសំខាន់នៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភថាជាគន្លឹះចំពោះការអភិវឌ្ឍ និងការតស៊ូមតិដើម្បីបន្តមានឥទ្ធិពលមកលើអ្នកធ្វើសេចក្តីសម្រេចចិត្ត។
- **ធ្វើការវិភាគស្ថាប័ននិងសមត្ថភាព**សម្រាប់របៀបវារៈវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភឆ្នាំ ២០៣០ ដើម្បីបញ្ជាក់ពីគណនេយ្យភាព ឆ្ពោះទៅ អនុវត្តយុទ្ធសាស្ត្រនានាទៅអនាគត។

- **ពិនិត្យមើលឡើងវិញនូវក្របខណ្ឌស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ** ដើម្បីពិនិត្យឡើងវិញនូវគោលបំណងនៃយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងភាពបន្ស៊ីគ្នាជាមួយក្របខណ្ឌផ្សេងទៀតតាមវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការនានា ដោយប្រើប្រាស់ការរៀនសូត្រពីការពិនិត្យជាយុទ្ធសាស្ត្រពាក់កណ្តាលអាណត្តិ (MTSR) នេះ។
- **បន្តការស្រាវជ្រាវ និងវិភាគ** ដើម្បីកែលម្អការតាមដានភាពងាយរងគ្រោះ និងការឆ្លើយតប និងជូនដំណឹងអំពីយុទ្ធសាស្ត្ររឹងមាំដែល"មិនបន្សល់ទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ"។

## ការរៀបចំផែនការ និងការអនុវត្ត ដោយមានការចូលរួម៖ មេរៀនទទួលបានពី MTSR

» អភិក្រមពិគ្រោះយោបល់ជាមួយ "**សង្គមទាំងមូល**" ដែលបង្កើនការចូលរួមនៅក្នុងដំណាក់កាលរៀបចំផែនការ ការអនុវត្ត និងការពិនិត្យឡើងវិញជាមួយអ្នកពាក់ព័ន្ធ ជាច្រើន។

» ការចូលរួមនៃអ្នកពាក់ព័ន្ធ**នៅថ្នាក់ក្រោមជាតិ** ដែលឆ្លុះបញ្ចាំងពីការវិភាគ និងការចាត់អាទិភាពនៅថ្នាក់តំបន់។

» **ដាក់មនុស្សឱ្យចំជំនាញ** - ធានាថាជនបង្គោលសំខាន់ៗត្រូវបានពង្រឹងសិទ្ធិអំណាចដើម្បីចូលរួមនៅក្នុងដំណើរការនេះទាំងមូល។

» រួមបញ្ចូលការពិគ្រោះយោបល់**ឯកទេស** (ជាក់លាក់តាមបញ្ហា) និង**ទូទៅ** (ពាក់ព័ន្ធនឹងប្រធានបទទាំងអស់) ដើម្បីធ្វើឱ្យមានតុល្យភាពនិងទិដ្ឋភាពរួមនៃអាទិភាពនានា។

» ប្រមូលផ្តុំ និងចែករំលែកមូលដ្ឋាន**ចំណេះដឹង**និងធ្វើការ**វិភាគបរិបទ។**

» ចែករំលែកព័ត៌មាន និងផ្សព្វផ្សាយចំណេះដឹងទាក់ទងនឹងបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភយុទ្ធសាស្ត្រនានា។

នៅពេលដែលការត្រៀមរៀបចំបានចាប់ផ្តើមសម្រាប់ការរៀបចំយុទ្ធសាស្ត្របន្ត ការយកចិត្តទុកដាក់ត្រូវតែផ្តោតលើទិសដៅយុទ្ធសាស្ត្រ ដែលបានកត់សម្គាល់នៅក្នុងការពិនិត្យឡើងវិញនេះ ទាក់ទងនឹងការលើកកម្ពស់ភាពទទួលបានស្បៀង និងកិច្ចគាំពារសង្គម ក៏ដូចជាអន្តរាគមន៍ដែលផ្តោតលើអាហារូបត្ថម្ភជាក់លាក់ និងដែលគិតគូរអំពីអាហារូបត្ថម្ភផងដែរ។ ប្រការនេះទាមទារឱ្យមានវិភាជន៍ធនធាននៅមូលដ្ឋានជាបន្ថែមទៀត នៅក្នុងការទទួលស្គាល់ការវិនិយោគសំខាន់ៗលើមូលធនមនុស្ស។ ចំណុចនេះអាចនឹងពង្រឹងបន្ថែមទៀត ដោយពង្រឹងអភិក្រមយកសិទ្ធិជាមូលដ្ឋានដែលទទួលស្គាល់ជាចំហនូវសិទ្ធិទទួលបានអាហារ និងអាហារូបត្ថម្ភគ្រប់គ្រាន់របស់ប្រជាពលរដ្ឋ និងការធានាឱ្យមានគណនេយ្យភាព ដើម្បីសម្រួលឱ្យសម្រេចបានការលុបបំបាត់ភាពអត់ឃ្លានឱ្យដល់កម្រិតសូន្យនៅត្រឹមឆ្នាំ ២០៣០។

ការប្រឈមនៃអសន្តិសុខស្បៀង និងអាហារូបត្ថម្ភ មានលក្ខណៈអន្តរវិស័យ និងច្រើនរូបភាព ដែលទាមទារឱ្យមានចំណាត់ការលើផ្នែកជាច្រើន និងនៅលំដាប់ថ្នាក់ខុសៗគ្នាក្នុងពេលជាមួយគ្នា។ ដោយផ្អែកលើយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដែលមានស្រាប់ ការពិនិត្យនេះ លើកស្នើឱ្យមានការផ្តោតលើវិស័យគន្លឹះចំនួនប្រាំ ដែលវិស័យគន្លឹះនីមួយៗរួមបញ្ចូលសេចក្តីពិស្តារបន្ថែមមួយចំនួននិងអនុសាសន៍ ដែលមានគោលដៅណែនាំសម្រាប់ការរៀបចំយុទ្ធសាស្ត្រគន្លឹះសម្រាប់ឆ្ពោះទៅឆ្នាំ ២០៣០។

១. **ភាពមានស្បៀង៖** ពង្រឹងការផ្តោតលើអាហារដែលមានគុណភាព ចម្រុះ ធន់នឹងការប្រែប្រួលអាកាសធាតុ និងកសិកម្មដែលគិតគូរពីអាហារូបត្ថម្ភ។

២. **ភាពទទួលបានស្បៀង៖** ការពង្រីកលទ្ធភាពទទួលបានស្បៀងដោយសមធម៌ជាងមុន (មិនទុកឱ្យនរណាម្នាក់នៅក្រោយការអភិវឌ្ឍ)។

៣. **ការបឺតស្រូបស្បៀង៖** ចាត់អាហារូបត្ថម្ភជាអាទិភាព និងដោះស្រាយការប្រឈមដែលលេចឡើងថ្មី។

៤. **ស្ថិរភាពស្បៀង៖** ត្រូវបន្តធានាភាពមានស្បៀង ភាពទទួលបានស្បៀង និងការបឺតស្រូបស្បៀងក្នុងករណីមានវិបត្តិ តាមរយៈវិធានការកាត់បន្ថយហានិភ័យ និងកិច្ចគាំពារសង្គម ។

៥. **ពង្រឹងការចាត់ចែងអភិបាលកិច្ច** លើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

# បញ្ជីឯកសារយោង

## ឯកសាររបស់ស្ថាប័នរដ្ឋាភិបាល


*Cabinet of Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of Cambodia. (2018). Speech Delivered at the Meeting to Commemorate the 39th*

*Anniversary of the 7-January Victory (7 January 1979-2018) [Unofficial Translation]*

*http://cnv.org.kh/39th-anniversary-7-january-victory/*

*Council for Agricultural and Rural Development, UNICEF & WFP (2013). The Economic Consequences of Malnutrition in Cambodia.*

*Council for Agricultural and Rural Development. (2017a). 2016 Food Security and Nutrition Report.*

*Council for Agricultural and Rural Development. (2017b). NSFSN MTSR National Consultation Workshop Report.*

*Council for Agricultural and Rural Development. (2017c). NSFSN MTSR Regional Consultation Workshop Report.*

*Leng Soklong/National Bank of Cambodia. (2016). Interest Rate Understanding and Possible Distortions of Interest Rate Cap in Case of Cambodia. Retrieved from https://www.nbc.org.kh/download_files/research_papers/english/8074InterestRateUnderstandingand-PossibleDistortionsofInterestRateCapinCambodia.pdf*

*Ministry of Agriculture Forestry and Fisheries. (2017). Annual Report and Direction 2017-2018 for Agriculture, Forestry and Fisheries 2016-2017.*

*Ministry of Agriculture, Forestry and Fisheries. (2014). Agricultural Sector Strategic Development Plan 2014-2018.*

*Ministry of Economy and Finance. (2016). Cambodia's Macroeconomic Progress: A Journey of 25 years. Retrieved from https://www.mef.gov.kh/documents/shares/Macroeconomic_Progress_at_ADB.pdf*

*Ministry of Education, Youth and Sport. (2015). Results of Grade Six Student Achievement from the National Assessment in 2013.*

*Ministry of Health. (2014). Fast Track Road Map for Improving Nutrition 2014-2020.*

*National Institute of Statistics. (2009). Cambodia Socio Economic Survey.*

*National Institute of Statistics. (2014). Cambodia Socio Economic Survey.*

*National Institute of Statistics, Directorate General for Health [Cambodia], and ORC Macro. (2001). Cambodia Demographic and Health Survey 2000. Phnom Penh, Cambodia, and Calverton, Maryland USA: National Institute of Statistics, Directorate General for Health, and ORC Macro.*

*National Institute of Statistics, Directorate General for Health, and ICF International. (2015). Cambodia Demographic and Health Survey 2014.*

*National Maternal and Child Health Center. (2016). National Nutrition Report.*

*Royal Government of Cambodia. (2013). Rectangular Strategy for Growth, Employment, Equity and Efficiency Phase III 2014-2018.*

*Royal Government of Cambodia. (2014a). National Strategy for Food Security and Nutrition 2014-2018.*

*Royal Government of Cambodia. (2014c). National Strategic Development Plan 2014-2018.*

*Royal Government of Cambodia. (2015). Climate Change Financing Framework.*

*Royal Government of Cambodia. (2016a). National Action Plan for the Zero Hunger Challenge in Cambodia 2016-2025.*

*Royal Government of Cambodia. (2016b). National Social Protection Policy Framework 2016-2025.*

*Royal Government of Cambodia. (2017). Mid-Term Review of the National Strategic Development Plan 2014-2018.*


## ឯកសាររបស់ស្ថាប័ននានា


*ASEAN. (2017). ASEAN Leaders' Declaration on Ending All Forms of Malnutrition. Retrieved from http://asean.org/asean-leaders-declaration-on-ending-all-forms-of-malnutrition/*

*Food and Agriculture Organization, United Nations Children's Fund and World Food Programme. (2016a). Household resilience in Cambodia: A Review of Livelihoods, Food Security and Health: El Niño Situation Analysis.*

*Food and Agriculture Organization, United Nations Children's Fund and World Food Programme. (2016b). Household Resilience in Cambodia II (unpublished).*

*Food and Agriculture Organization. (2017a). Retrieved from https://data.worldbank.org/indicator/SN.ITK.DEFC.ZS?locations=KH*

*Food and Agriculture Organization. (2017b). The Impact of Gender Policy Processes on the Right to Food: The Case of Cambodia.*

*Garschagen, M., Hagenlocher, M., Comes, M., Dubbert, M., Sabelfeld, R., Lee, Y. J., Birkmann, J. (2016). World Risk Report. Bündnis Entwicklung Hilft and UNU-EHS.*

*High Level Panel of Experts on Food Security. (2017). Nutrition and food systems.*

*International Food Policy Research Institute (IFPRI). (2016). Global Nutrition Report 2016: From Promise to Impact: Ending Malnutrition by 2030. Washington, DC.*

*International Food Policy Research Institute. (2013). Cambodian Agriculture Adaptation to Climate Change Impact.*

*Multidisciplinary Digital Publishing Institute. (2016). The High Prevalence of Anemia in Cambodian Children and Women Cannot Be Satisfactorily Explained by Nutritional Deficiencies or Hemoglobin Disorders.*

*SUN Civil Society Network. (2017). SDG Toolkit and Scorecard. Retrieved from http://scalingupnutrition.org/news/new-sdg-toolkit-and-scorecard-equips-civil-society-with-tools-needed-to-advocate-for-better-nutrition-policy/UN. (2015). MDG Country Progress Snapshot-Cambodia.*

*United Nations Children's Fund. (2015). Multi-Sectoral Approaches to Nutrition: Nutrition-specific and Nutrition-sensitive Interventions to Accelerate Progress.*

*United Nations Children's Fund. (2016b). Maternal, Newborn and Child Health and Nutrition.*

*United Nations Development Programme. (2016). Human Development Report 2016, http://report.hdr.undp.org/*

*United Nations Development Programme. (2017). In and Out of Poverty: An Analysis of Cambodian Poverty and Vulnerability Dynamics Between 2004 and 2014.*

*United Nations Population Fund. (2014). Linkage to socio-economic and environmental issues.*

*United Nations. (2016). Sustainable Development Goal Indicators.*

*United Nations. (n.d.). Sustainable Development Goal 2. Retrieved from https://sustainabledevelopment.un.org/sdg2*

*von Grebmer, K., Bernstein, J., Hossain, N., Brown, T., Prasai, N., Yohannes, Y., . . . Foley, C. (2017). 2017 Global Hunger Index: The inequalities of hunger. Washington, D.C.; Bonn; and Dublin: International Food Policy Research Institute, Welthungerhilfe, and Concern Worldwide. https://doi.org/10.2499/9780896292710*

*von Grebmer, K., Saltzman, A., Birol, E., Wiesmann, D., Prasai, N., Yin, S., . . . A., S. (2014). 2014 Global hunger index: Getting to zero hunger. Bonn, Washington, D.C., and Dublin: Welthungerhilfe, International Food Policy Research Institute, and Concern Worldwide. http://dx.doi.org/10.2499/9780896299580*

*World Bank. (2013). Where Have all the Poor Gone? Cambodia Poverty Assessment 2013.*

*World Bank. (2017). Cambodia Systematic Country Diagnostic.*

*World Food Programme. (2017a). An Analysis of Urban Vulnerabilities (a study in support of the MTSR).*

*World Food Programme. (2017b). Challenges and Opportunities for Nutrition and Food Security - Analytical study in support of the MTSR.*

*World Food Programme. (2017c). Development Financing Analysis for Food Security and Nutrition (a study in support of the MTSR).*

*World Food Programme. (2017d). Fill the Nutrient Gap, Cambodia.*

*World Food Programme. (2017e). Gender Review of Food Security and Nutrition Policies in Cambodia (2017).*

*World Food Programme. (2017f). Private Sector Analysis (a study in support of the MTSR).*

*World Food Programme. (2017g). Resilience and recovery from shocks.*

*World Health Organization and United Nations Children's Fund. (2015). Joint Monitoring Program for Water Supply and Sanitation.*

ទីស្តីការគណៈរដ្ឋមន្ត្រី
#41 មហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ប្រអប់សំបុត្រលេខ៖ 2470 ទូរសារ/ទូរស័ព្ទ (+855) 23 426 824
អ៊ីម៉ែល៖ info@card.gov.kh គេហទំព័រ៖ www.card.gov.kh